សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីក្នុងរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ពេជ បញ្ញា**

សាស្ត្រាចារ្យណែនាំ
លោក **ម៉ៅ មុណ្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ពេជ បញ្ញា ជានិស្សិតជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាដំបូងខ្ញុំបាទសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជូន លោកពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើត និងអនាគតមកដល់រូបកូនរហូតមកទល់ពេលនេះ ជាពិសេសរូបលោកទាំង ពីរ តែងតែទំនុកបម្រុងដល់កូនគ្រប់បែបយ៉ាង រួមទាំង ប្រាក់កាក់ ស្មារតី និងជាកម្លាំងចិត្ត ដែលបង្កើនការតស៊ូរបស់កូនរហូតដល់ពេលបច្ចុប្បន្ន ទាំងនេះសុទ្ធសឹងតែជាគុណូបការៈដ៏ថ្លៃថ្លារបស់លោកឪពុក និងអ្នកម្តាយ ដែលមិនអាចមានអ្វីនឹងកាត់ថ្លៃបាន។

សូមថ្លែងអំណរអរគុណជាពិសេសលោកគ្រូ ម៉ៅ បុណ្ណា ដែលលោកគ្រូជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាមួយនេះឡើង ដោយបានចំណាយពេលដ៏មានតម្លៃរបស់លោកគ្រូក្នុងការបង្ហាត់បង្រៀន និងបានផ្តល់ដំបូន្មានល្អៗ សម្រាប់បើកផ្លូវក្នុងការណែនាំដល់រូបកូន។ ជាពិសេសដែរនោះសូមថ្លែងអំណរអរគុណដល់លោកគ្រូ-អ្នកគ្រូទាំងអស់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្រៀនយ៉ាងយកចិត្តទុក ក្នុងការផ្តល់ចំណេះដឹងសម្រាប់រយៈពេល៤ឆ្នាំកន្លងមកដល់កូនសិស្សដែរ។

សូមថ្លែងអំណរអរគុណឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកឧត្តមបណ្ឌិត លុយ ចណ្ណា និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងបុគ្គលិកទាំងអស់ ដែលមានវត្តមាននៅសាកលវិទ្យាល័យ ដែលបានខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍ និងពង្រឹងធនធានមនុស្ស ដែលមានចំណាប់អារម្មណ៍ក្នុងវិស័យអ្នកសិក្សាច្បាប់ ក៏ដូចជាបានព្យាយាមពង្រីកបន្ថែមសមត្ថភាពដល់សិស្សនិស្សិតគ្រប់រូប ដែលជាទំពាំងស្នងឫស្សីរបស់ប្រទេស តាមរយៈសកម្មភាពមួយចំនួនដូចជាការចូលរួមវេទិកាទាក់ទងនឹងវិស័យច្បាប់ កម្មវិធីប្រកួតប្រជែង និងកម្មវិធីសិក្សាផ្សេងៗ ជាច្រើនទៀត។

ហើយក៏មិនភ្លេចដែរនោះ គឺការថ្លែងអំណរអរគុណដល់ម្ចាស់ស្នាដៃនៃសៀវភៅទាំងអស់ ក៏ដូចជាអ្នករៀបរាង អ្នកបកប្រែ អ្នកកែសម្រួល និងស្នាដៃក្រឹត្យក្រមនៃច្បាប់ទាំងអស់ ដែលជាមូលដ្ឋានក្នុងការផ្តល់ជាទិន្នន័យ និងផ្តល់ជាគំនិតសម្រាប់ធ្វើឱ្យការសិក្សាស្រាវជ្រាវ និងការរៀបរាងសារណាមួយនេះ មានភាពកាន់តែប្រសើរឡើង។

ជាចុងក្រោយ ខ្ញុំបាទសូមលើកម្រាមដៃដប់ បួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកទាំងអស់ ឱ្យតាមជួយថែរក្សាការពារ លោកពុក និងអ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់នៅសាកលវិទ្យាល័យ ឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាអស់រយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកន្លងមក ខ្ញុំបាទបានយល់យ៉ាងច្បាស់ថា មុខវិជ្ជា រដ្ឋប្បវេណី គឺជាមុខវិជ្ជាមួយដ៏សំខាន់សម្រាប់គ្រប់គ្រងការរស់នៅរបស់បុគ្គលស៊ីវិលក្នុងសង្គម ព្រោះមុខវិជ្ជារដ្ឋប្បវេណីនេះ មិនត្រឹមតែជាមុខវិជ្ជាសម្រាប់តែបង្ហាញពីសកម្មភាព និងសិទ្ធិរបស់បុគ្គលគ្រប់រូបប៉ុណ្ណោះទេ ប៉ុន្តែមុខវិជ្ជានេះគឺជាមូលដ្ឋានដ៏សំខាន់ក្នុងការស្វែងរកយុត្តិធម៌ដល់បុគ្គលគ្រប់រូបដែរ។ ដោយបានបញ្ចប់មុខវិជ្ជា២ គឺមុខវិជ្ជារដ្ឋប្បវេណី និងមុខវិជ្ជានីតិវិធីរដ្ឋប្បវេណី ខ្ញុំបាទមានចំណាប់អារម្មណ៍ជាខ្លាំងទៅលើមុខវិជ្ជាស៊ីវិល រដ្ឋប្បវេណីមួយនេះ ក៏ដូចជាមានឱកាសទទួលបានសិទ្ធិសរសេរសារណាដែរនោះ ខ្ញុំបាទក៏បានសម្រេចចិត្តយកមុខវិជ្ជាមួយនេះ ធ្វើជាគោលដើម្បីសរសេរសារណាដោយជ្រើសយកប្រធានបទមានចំណងជើងថា "នីតិវិធីក្នុងរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង" មកសរសេរជាសារណាបញ្ចប់ការសិក្សា។

សារណាមួយនេះ ដែលបានរៀបរាង និងស្រាវជ្រាវឡើងដោយខ្ញុំបាទ អាចនៅមានកម្រិតខ្វះចន្លោះនៅឡើយ ដែលបង្កឱ្យមានកំហុសខុសឆ្គងដោយអចេតនាលើ ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លាឃ្លោង វេយ្យាករណ៍ ឬខ្លឹមសារមិនបានត្រឹមត្រូវតាមក្បួនច្បាប់ ដោយប្រការណាមួយ ខ្ញុំបាទសូមមេត្តាខន្តីអភ័យទោសពីសំណាក់ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា និងមិត្តអ្នកអានទាំងអស់ ដោយហេតុថា ចំណេះដឹង និងបទពិសោធន៍របស់ខ្ញុំបាទមានកម្រិតនៅឡើយ។ ខ្ញុំបាទសូមទទួលយកការណែនាំ និងការរិះគន់ទាំងអស់ ពីកំហុសខុសឆ្គងដែលមាននៅលើអត្ថបទមួយនេះ ដែលខ្ញុំបាទបង្កើតឡើង ដោយចេតនាក្ដី ឬអចេតនាក្ដី ដើម្បីស្ថាបនា និងពង្រឹងសមត្ថភាពបន្ថែម។

ជាចុងក្រោយខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងក្លាយជាអត្ថបទដ៏មានតម្លៃ និងមានសារៈប្រយោជន៍សម្រាប់មិត្តអ្នកអានគ្រប់រូប និងជាពិសេសបានបន្សល់ទុកជាឯកសារមួយសម្រាប់ប្អូនៗ និស្សិតជំនាន់ក្រោយ ដើម្បីសិក្សាស្រាវជ្រាវបន្តក្នុងការយល់ដឹងអំពីដំណើរការ និងនីតិវិធីនៅក្នុងរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង។ ក្នុងឱកាសចុងក្រោយនេះដែរ ខ្ញុំបាទ សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជូនមិត្តអ្នកអាន និងសូមជូនពរដល់មិត្តអ្នកអានទាំងអស់ឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១៖ បណ្តឹងរដ្ឋប្បវេណី**

**ផ្នែកទី១៖ ដំណើរការនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី** ........ ៤

**កថាខណ្ឌទី១៖ ទម្រង់ពាក្យបណ្តឹង** ........ ៤

១. ចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹង ........ ៥

២. ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹង ........ ៦

**កថាខណ្ឌទី២៖ ប្រភេទនៃបណ្តឹងរដ្ឋប្បវេណី** ........ ៧

១. បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ........ ៨

២. បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ........ ៨

៣. បណ្តឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត ........ ៩

**ផ្នែកទី២៖ ភាគីបណ្តឹងរដ្ឋប្បវេណី** ........ ១០

**កថាខណ្ឌទី១៖ សមត្ថភាពភាគី** ........ ១០

១. ភាគីដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹង ........ ១១

២. ករណីកង្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ........ ១២

**កថាខណ្ឌទី២៖ អ្នកតំណាងតាមផ្លូវបណ្តឹង** ........ ១៣

១. អ្នកតំណាងដែលច្បាប់បានកំណត់ ........ ១៤

២. អ្នកតំណាងដោយអាណត្តិ ........ ១៥

**ជំពូកទី២៖ ដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១**

**ផ្នែកទី១៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ១៦

**កថាខណ្ឌទី១៖ សំណុំឯកសារត្រៀម** ........ ១៦

១. ឯកសារត្រៀមសម្រាប់សេចក្តីថ្លែងការណ៍ ........ ១៧

២. ភស្តុតាង ........ ១៧

**កថាខណ្ឌទី២៖ ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ១៧
១. សកម្មភាពរបស់តុលាការ ........ ១៨
២. សកម្មភាពរបស់ភាគី ........ ១៩
**ផ្នែកទី២៖ ការទាញហេតុផលដោយផ្ទាល់មាត់** ........ ២០
**កថាខណ្ឌទី១៖ មុនអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់** ........ ២០
១. កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ........ ២០
២. ភស្តុតាងត្រៀម ........ ២១
**កថាខណ្ឌទី២៖ អំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់** ........ ២១
១. សេចក្តីថ្លែងការណ៍របស់ភាគី ........ ២១
២. ការពិនិត្យភស្តុតាង ........ ២២
៣. ការវិនិច្ឆ័យរបស់ចៅក្រម ........ ២៣
**ជំពូកទី៣៖ ការបញ្ចប់បណ្តឹង**
**ផ្នែកទី១៖ ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី** ........ ២៥
**កថាខណ្ឌទី១៖ ការបញ្ចប់បណ្តឹងដោយភាគី** ........ ២៥
១. ការដកពាក្យបណ្តឹង ........ ២៥
២. ការសះជាតាមផ្លូវបណ្តឹង ........ ២៦
៣. ការលះបង់ ឬការទទួលស្គាល់ការទាមទារ ........ ២៧
**កថាខណ្ឌទី២៖ ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ** ........ ២៧
១. មរណភាពរបស់ភាគី ........ ២៧
២. ករណីដែលដើមចោទ និងចុងចម្លើយក្លាយជាបុគ្គលតែម្នាក់ ........ ២៧
**ផ្នែកទី២៖ ការបញ្ចប់បណ្តឹងដោយសកម្មភាពតុលាការ** ........ ២៨
**កថាខណ្ឌទី១៖ ការប្រកាសសាលក្រម** ........ ២៨
១. ប្រភេទនៃសាលក្រម ........ ២៨
២. ការប្រកាសសាលក្រមចុងក្រោយ ........ ៣០

**ផ្នែកទី៣៖ នីតិវិធីនៃការអនុវត្តផ្សេងទៀត** ........ ៣១
**កថាខណ្ឌទី១៖ នីតិវិធីដាស់តឿន** ........ ៣១
១. លក្ខខណ្ឌចំពោះនីតិវិធីនៃការដាស់តឿន ........ ៣១
២. អានុភាពនៃដីកាសម្រេចដាស់តឿន ........ ៣២
**កថាខណ្ឌទី២៖ ការអនុវត្តដោយបង្ខំ** ........ ៣២
១. លក្ខខណ្ឌចំពោះការអនុវត្តដោយបង្ខំ ........ ៣៣
២. កិច្ចការនៅពេលដែលអនុវត្តដោយបង្ខំ ........ ៣៣
**កថាខណ្ឌទី៣៖ ការចាត់ចែងរក្សាការពារ** ........ ៣៤
១. អត្ថន័យ និងគោលបំណង ........ ៣៤
២. ប្រភេទនៃការចាត់ចែងរក្សាការពារ ........ ៣៤
**សេចក្ដីសន្និដ្ឋាន** ........ ៣៥
**អនុសាសន៍** ........ ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅសតវត្សទី២១ ឈានចូលសតវត្សទី២២នេះ ប្រទេសកម្ពុជា ដែលមានផ្ទៃដីសរុប ១៨១.០៣៥ គីឡូម៉ែត្រការ៉េ និងជាប្រទេសមួយដែលកំពុងអភិវឌ្ឍដែរនោះ បានរីកចម្រើនជាខ្លាំងលើគ្រប់វិស័យ និងកំពុងបន្តឈានជើងទៅកាន់ពិភពលោកម្តងបន្តិចៗ ជាបន្តបន្ទាប់។ ព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីបានបញ្ចប់សង្គ្រាមក្នុងឆ្នាំ១៩៧៩ រួចមក រដ្ឋាភិបាលបានបន្តការខិតខំប្រឹងប្រែងក្នុងការបង្កើតច្បាប់ផ្សេងៗ ជាច្រើន ដើម្បីគ្រប់គ្រងសន្តិសុខ និងរក្សាសន្តិភាពនៅក្នុងសង្គមឱ្យមានស្ថេរភាពឡើងវិញ និងបានបង្កើតប្រព័ន្ធយុត្តាធិការ ក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋរបស់ខ្លួន ក្នុងករណីដែលវិវាទកើតមានឡើង។ ស្របពេលជាមួយគ្នានេះដែរ កំណើនប្រជាជនបានបន្តកើនឡើងកាន់តែច្រើនក្នុងពេលបច្ចុប្បន្ន វិវាទដែលបង្កឡើងដោយសកម្មភាពបុគ្គលឯកជន ក៏កាន់តែបន្តកើតមានឡើងជាលំដាប់ និងជាបន្តបន្ទាប់ដែរ ដែលជាមូលហេតុនាំឱ្យមានការបង្កើតច្បាប់រដ្ឋប្បវេណីឡើង ក្នុងគោលបំណងគ្រប់គ្រង និងកំណត់សកម្មភាពរបស់បុគ្គលទាំងនោះ និងស្វែករកយុត្តិធម៌ជូនបុគ្គលដែលបានទទួលរងគ្រោះ។

ដើម្បីឆ្លើយតបនឹងការទាមទារ និងការចង់បានរបស់ប្រជាពលរដ្ឋ ក្នុងការបង្កើតឱ្យមានតុលាការដែលជម្រះក្តីដោយផ្អែកលើភាពសុក្រិតយុត្តិធម៌ និងត្រឹមត្រូវឆាប់រហ័សខាងផ្នែកឯកជននោះ រដ្ឋាភិបាលនៃប្រទេសកម្ពុជាយើង បានបង្កើតកិច្ចសហប្រតិបត្តិការជាមួយប្រទេសដៃគូជាអន្តរជាតិ គឺទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ដែលហៅកាត់ថា JICA បានរួមដៃគ្នាក្នុងការបង្កើតក្រមទាំងពីរនេះឡើង គឺក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី ដើម្បីបម្រើប្រព័ន្ធយុត្តាធិការ និងប្រជាជនកម្ពុជារហូតមកទល់ពេលបច្ចុប្បន្ន។ ក្រមទាំងពីរបានដើរតួដ៏សំខាន់ក្នុងការកម្រិតសកម្មភាពរបស់បុគ្គល រួមទាំងបុគ្គលឯកជន និងបុគ្គលអនុវត្តច្បាប់នេះដែរ បើទោះបីជាក្រមទាំងពីរនេះ ដើរតួមិនដូចគ្នាក៏ដោយ ប៉ុន្តែគោលដៅ និងគោលបំណងនៃក្រមនេះ គឺបង្កើតឡើងសម្រាប់ការពារផលប្រយោជន៍នៃគ្រប់សកម្មភាពរបស់បុគ្គលឯកជនទាំងអស់។

ដោយឡែក ក្រមរដ្ឋប្បវេណី គឺជាក្រមដែលមនុស្សទូទៅស្ទើរទាំងអស់គ្នាយល់ថា ជាប្រភេទច្បាប់ដែលមានលក្ខណៈស្មុគស្មាញ ស៊ាំញ៉ាំ និងពិបាកក្នុងបកស្រាយ ពាក្យពេចន៍ ពិបាកក្នុងការស្វែងយល់ មិនត្រឹមតែប៉ុណ្ណោះដំណើរការរឿងក្តីរដ្ឋប្បវេណីផ្ទាល់ ក៏មានការលំបាក និងស្មុគស្មាញមិនចាញ់ពីអ្វី ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែរ ព្រោះថាទិដ្ឋភាពនៃការអនុវត្តផ្ទាល់ មិនស្រួលដូចអ្វីដែលយើងបានអាន ឬសរសេរនៅក្នុងក្រមឡើយ បើយើងមិនអាចយល់ច្បាស់ពីអ្វីដែលច្បាប់ចង់បង្ហាញនោះទេ នោះនាំឱ្យការអនុវត្តច្បាប់មានលក្ខណៈផ្ទុយនឹងច្បាប់ និងអាចបង្កជាផលប៉ះពាល់ដល់បុគ្គលដែលពាក់ព័ន្ធបាន។ ដោយសារតែមើលឃើញនិងផ្អែកលើបញ្ហាទាំងនេះ ដែលកើតមានចំពោះប្រជាពលរដ្ឋទូទៅ ក៏ដូចជាសិស្សនិស្សិតច្បាប់ជំនាន់ថ្មី ដែលពិបាកក្នុងការស្វែងយល់ និងសិក្សាដំណើរការរឿងក្តីរដ្ឋប្បវេណីនេះ ខ្ញុំបាទក៏មានចំណាប់អារម្មណ៍លើកយក

ប្រធានបទសារណាមួយស្ដីពី " នីតិវិធីក្នុងរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង " មកធ្វើការបកស្រាយ ដើម្បីឱ្យមានភាពងាយស្រួលយល់ និងឆាប់ចាប់បានច្រើនជាងមុន។

ដោយផ្អែកលើមូលដ្ឋានច្បាប់ជាធរមាន និងការអនុវត្តជាក់ស្ដែងនៅប្រទេសកម្ពុជាយើងកន្លងមក មានមតិជាច្រើនបានលើកឡើងពីបញ្ហានៃដំណើរការរឿងក្ដីរដ្ឋប្បវេណី និងមានចំណោទចោទសួរជុំវិញប្រធានបទស្ដីអំពី " នីតិវិធីក្នុងរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង " រួមមានដូចជា៖

១. យើងគួរសរសេរ ឬដាក់ពាក្យបណ្ដឹងក្នុងរឿងក្ដីរដ្ឋប្បវេណីយ៉ាងដូចម្ដេច?

២. តើដំណើរការនៅក្នុងសវនាការរឿងក្ដីរដ្ឋប្បវេណី មានដំណាក់កាលអ្វីខ្លះ?

៣. តើការប្រកាសសាលក្រមស្ថាពររបស់តុលាការ មានអានុភាពអនុវត្តយ៉ាងដូចម្ដេច?

គោលបំណង និងខ្លឹមសារនៃសារណាបញ្ចប់ការសិក្សាមួយនេះ បានសិក្សា និងស្រាវជ្រាវ ផ្ដោតសំខាន់លើចំណុចធំៗ មួយចំនួនដូចខាងក្រោម៖

- ផ្ដល់ចំណេះដឹងទាក់ទងនឹងការដាក់ពាក្យបណ្ដឹងរឿងក្ដីរដ្ឋប្បវេណីទៅកាន់តុលាការ ដែលមានចំណុចមួយចំនួនដូចជារបៀបនៃការសរសេរពាក្យបណ្ដឹង និងប្រភេទពាក្យបណ្ដឹងជាដើម
- យល់ដឹងច្បាស់លាស់ពីបុគ្គល ដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ដែលរួមបញ្ចូលចំណុចមួយចំនួនដូចជាភាគីបណ្ដឹង និងអ្នកតំណាង
- សេចក្ដីពន្យល់ និងណែនាំពីដំណាក់កាលនីមួយៗ ក្នុងដំណើរការរឿងក្ដីរដ្ឋប្បវេណីជូនដល់ប្រិយមិត្តអ្នកអាន ដើម្បីងាយស្រួលទទួលបានចំណេះដឹងបន្ថែមជាងមុន
- អំពីសាលក្រមរបស់សាលាជម្រះក្ដី និងការអនុវត្តសាលក្រមក្នុងដែនដី ព្រះរាជាណាចក្រកម្ពុជាយើង ដោយស្ថានប័នតុលាការ

សារៈសំខាន់ក្នុងការស្រាវជ្រាវអត្ថបទមួយនេះ គឺដើម្បីឱ្យបងប្អូនមិត្តអ្នកអាន ងាយស្រួលក្នុងការចាប់យកអត្ថន័យក្នុងអត្ថបទផ្ទាល់ ព្រោះថាក្នុងអត្ថបទមួយនេះបានសរសេរពីភាពជាក់ស្ដែង របៀបរបបនៃការកាត់ក្ដីក្នុងសវនាការ និងយុទ្ធសាស្ត្រនៃការអនុវត្តរបស់សាលាដំបូង ដែលថ្ងៃក្រោយអត្ថបទមួយនេះ អាចនឹងបានជាប្រយោជន៍ដល់មិត្តអ្នកអានគ្រប់រូប នៅក្នុងវិស័យច្បាប់ផ្ទាល់ ជាពិសេសសម្រាប់និស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ។

អត្ថបទបញ្ចប់ការសិក្សាមួយនេះ គឺបានលើកឡើងពីការអនុវត្តជាក់ស្ដែងដែលស្ថិតនៅត្រឹមតែដែនដីនៃព្រះរាជាណាចក្រកម្ពុជាយើង និងមានវិសាលភាពគ្របដណ្ដប់ ទៅលើតែនីតិវិធីរឿងក្ដីរដ្ឋប្បវេណីនៅក្នុងសាលាដំបូងតែប៉ុណ្ណោះ ហើយអត្ថបទនេះទៀតសោត បានសិក្សាស្រាវជ្រាវចេញពីច្បាប់ជាធរមាន គឺក្រមនីតិវិធីរដ្ឋ

ប្បវេណី ចាប់ពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននៃការស្រាវជ្រាវ។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវមួយនេះ បានដកស្រង់ចេញពីប្រភពសំខាន់២ គឺទី១ឯកសារចម្បង ដែលមានដូចជាច្បាប់ដែលបានចូលជាធរមាន លិខិតបទដ្ឋានគតិយុត្តនានា និងទី២ឯកសារបន្ទាប់បន្សំ រួមមានសៀវភៅ ឬឯកសារមេរៀនរបស់សាស្ត្រាចារ្យ សេចក្តីពន្យល់ក្រម វចនានុក្រមខ្មែរ សៀវភៅតាមបណ្ណាគារ ឬយកពីបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាដើម។

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហាដែលបានលើកឡើងខាងលើ ដែលវាជាឧបសគ្គរាំងដល់ចំណេះដឹងទូទៅរបស់ប្រជាជនយើង និងដើម្បីជាការងាយស្រួលក្នុងការបកស្រាយបំភ្លឺអត្ថបទសារណាបញ្ចប់ការសិក្សាដែលស្តីអំពី " នីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូង " ខ្ញុំបាទសុំធ្វើការបែងចែកជា៣(បី)ជំពូកដូចខាងក្រោម៖

- ជំពូកទី១៖ បណ្តឹងរដ្ឋប្បវេណី
- ជំពូកទី២៖ ដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១
- ជំពូកទី៣៖ ការបញ្ចប់បណ្តឹង

ដែលមានសេចក្តីអធិប្បាយដូចខាងក្រោម។

# ជំពូកទី១
# បណ្ដើខរដ្ឋប្រទេណី

# ជំពូកទី១៖ បណ្តឹងរដ្ឋប្បវេណី

ការស្វែងយល់ពីបណ្តឹង គឺជារឿងដ៏សំខាន់មួយដំណាក់កាលដែរក្នុងរឿងក្តី ព្រោះដើម្បីដំណើរការនៃការកាត់ក្តីមួយបាន លុះត្រាតែមានការធ្វើពាក្យបណ្តឹងទៅកាន់តុលាការ ដើម្បីឱ្យតុលាការដឹងឮជាមុនសិន ទើបយើងអាចបន្តដំណាក់កាលផ្សេងទៀតបាន។ ដោយឡែកបើយើងក្រឡេកមកមើល បណ្តឹងរដ្ឋប្បវេណី ត្រូវបានឱ្យនិយមន័យថា គឺជាបណ្តឹងមួយដែលច្បាប់ទទួលស្គាល់ និងអនុញ្ញាតសម្រាប់ជនគ្រប់រូប អាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល ក្នុងការពឹងពាក់ស្ថាប័នតុលាការ ចំពោះវិវាទរដ្ឋប្បវេណី ដើម្បីឱ្យតុលាការជួយដោះស្រាយបញ្ហាដែលកើតមានឡើង ដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។[1] ចំណុចដែលគួរស្វែងយល់ មុននឹងឈានទៅដល់ការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីដែលមាន២ផ្នែកសំខាន់ៗ ដូចជាដំណើរការនៃការដាក់ពាក្យបណ្តឹង(ផ្នែកទី១) និងភាគីបណ្តឹង(ផ្នែកទី២)។

## ផ្នែកទី១៖ ដំណើរការនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី

មូលហេតុដែលនាំឱ្យមានដំណើរការនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ព្រោះរដ្ឋាភិបាលខិតខំប្រឹងប្រែងធ្វើយ៉ាងណាការពារឱ្យបានស្ថេរភាពនៃភាពយុត្តិធម៌ក្នុងសង្គម ហើយច្បាប់ខ្លួនឯងផ្ទាល់ គឺក្រមនីតិវិធីរដ្ឋប្បវេណី មានគោលបំណងចង់ឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិបុគ្គលឯកជន[2] និងមានគោលដៅជុសជុលការខូចខាតដល់ជនរងគ្រោះ ឱ្យបានសមល្មមទៅនឹងព្យសនកម្ម ដែលបង្កឡើងដោយអំពើល្មើសរបស់ភាគីម្ខាងទៀត[3]។ ដូច្នេះ ដើម្បីដំណើរការនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីបាន យើងត្រូវសិក្សាស្វែងយល់ជាមុនពីទម្រង់ពាក្យបណ្តឹង(កថាខណ្ឌទី១) និងប្រភេទនៃបណ្តឹង(កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ ទម្រង់ពាក្យបណ្តឹង

ទម្រង់នៃពាក្យបណ្តឹង គឺជាបណ្តុំឯកសារដែលត្រូវរៀបចំ និងបំពេញឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ទើបតុលាការសម្រេចទទួលយក ដោយឆ្លងកាត់ដំណាក់កាត់នៃការត្រួតពិនិត្យបណ្តឹងដែរ[4] បើក្នុងករណីតុលាការត្រួតពិនិត្យ និងរកឃើញថា ទម្រង់ពាក្យបណ្តឹងដែលបានដាក់ជូននោះ មានលក្ខណៈខ្វះខាត មិនពេញ

---

[1] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា២ (គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី សិទ្ធិពឹងពាក់តុលាការ) កថាខណ្ឌទី២។

[2] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា២ (គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី សិទ្ធិពឹងពាក់តុលាការ) កថាខណ្ឌទី១។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ០៦ សីហា ២០០៧ មាត្រា២ (បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី) កថាខណ្ឌទី៣។

[4] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៧៨ (ការពិនិត្យពាក្យបណ្តឹង) កថាខណ្ឌទី១ និងកថាខណ្ឌទី២។

លេញត្រឹមត្រូវ នោះតុលាការនឹងទុកពេលឱ្យកែតម្រូវ ឬអាចលើកបណ្ដឹងចោលបានក្នុងករណីមិនព្រមធ្វើការកែតម្រូវ[5]។ បញ្ហាទាំងអស់នេះហើយ ដែលជាមូលហេតុនាំឱ្យយើងត្រូវសិក្សាជាមុន ចំណុចត្រូវសរសេរក្នុងពាក្យបណ្ដឹង(១) ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្ដឹង(២) និងឯកសារភ្ជាប់(៣)។

**១. ចំណុចត្រូវសរសេរក្នុងពាក្យបណ្ដឹង**

ថ្វីត្បិតតែគំរូនៃពាក្យបណ្ដឹងមានបោះពុម្ពរួចជាស្រេចហើយក៏ដោយ ប៉ុន្តែក៏នៅតែមានចន្លោះ ដែលភាគីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវធ្វើការបំពេញជាចាំបាច់ ដែលរួមមានដូចជាអំពីភាគី(១.១) & កម្មវត្ថុ និងមូលហេតុនៃការទាមទារ(១.២)។

**១.១ អំពីភាគី**

នៅក្នុងគំរូនៃពាក្យបណ្ដឹង តែងតែបានបន្សល់ទុកចន្លោះសម្រាប់ឱ្យភាគីធ្វើការបំពេញព័ត៌មានផ្ទាល់ខ្លួនសមាសភាពរបស់ភាគីម្ខាងទៀត និងអង្គហេតុសំខាន់ៗ ដែលច្បាប់បានតម្រូវឱ្យមាននៅក្នុងគំរូពាក្យបណ្ដឹងនោះរួមមានដូចខាងក្រោម៖

- សរសេរ ឬបំពេញ ឈ្មោះ នាមករណ៍៖ ឈ្មោះ នាមករណ៍របស់ភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ គឺពិតជាមានភាពចាំបាច់ខ្លាំងណាស់ក្នុងពាក្យបណ្ដឹង ព្រោះដើម្បីកំណត់បានអត្តសញ្ញាណរបស់បុគ្គលរងគ្រោះ ឬជនខូចប្រយោជន៍ និងជាការតម្រូវរបស់ច្បាប់ដែរ ដែលកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នៃមាត្រា៧៥ កថាខណ្ឌទី២ ចំណុច(ក)
- ក្នុងករណីភាគីជានីតិបុគ្គល៖ បើភាគីបណ្ដឹងជានីតិបុគ្គលវិញ នោះយើងមិនអាចសរសេរ ឬបំពេញឈ្មោះបុគ្គល ដែលមានវត្តមាន ឬធ្វើការនៅក្នុងក្រុមហ៊ុននៃនីតិបុគ្គលទាំងអស់នោះបានទេ និងមិនអាចយកឈ្មោះ ឬនាមករណ៍ក្រុមហ៊ុនរបស់នីតិបុគ្គលនោះមកសរសេរបានឡើយ ពោលគឺត្រូវយកឈ្មោះ ឬនាមករណ៍នៃអ្នកតំណាងរបស់ក្រុមហ៊ុននៃនីតិបុគ្គលនោះ មកសរសេរជំនួសវិញ
- ទីតាំង អាស័យដ្ឋាន៖ នៅក្នុងគំរូនៃពាក្យបណ្ដឹងក៏តម្រូវឱ្យមានការបំពេញទីតាំង អាស័យដ្ឋានរបស់ភាគីដែរ ដោយការកំណត់អាសយដ្ឋាននោះត្រូវមានភាពត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីឱ្យតុលាការមានភាពងាយស្រួលក្នុងការបញ្ជូនព័ត៌មាននានាទៅកាន់ភាគី ក្នុងរយៈពេលឆាប់រហ័ស និងមិនមានការកកស្ទះឃឹតយ៉ាវដល់ការបញ្ជូនពាក្យបណ្ដឹងដែរ។[6]

[5] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៧៨ (ការពិនិត្យពាក្យបណ្ដឹង) កថាខណ្ឌទី២។

[6] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៧៥ (របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) កថាខណ្ឌទី២ ចំណុច(ក)។

**១.២ កម្មវត្ថុ និងមូលហេតុនៃការទាមទារ**

នៅក្នុងពាក្យបណ្ដឹងដែលនឹងត្រូវដាក់ជូនតុលាការ ចំណុចដែលសំខាន់បំផុតនោះ គឺការសរសេរបញ្ជាក់អំពីកម្មវត្ថុ និងមូលហេតុនៃការទាមទារ ពីព្រោះថាចំណុចនេះនឹងបង្ហាញឱ្យតុលាការបានឃើញពីមូលហេតុដែលយើងធ្វើបណ្ដឹង និងបានដឹងពីចំណុចនៃការទាមទារ ក៏ដូចជាអង្គហេតុដែលនាំឱ្យមានវិវាទតាមផ្លូវច្បាប់កើតមានឡើងដែរ។ នៅក្នុងគំរូនៃពាក្យបណ្ដឹងនោះ ភាគីដែលជាដើមបណ្ដឹងរដ្ឋប្បវេណី គប្បីត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ពី៖

- កម្មវត្ថុនៃការទាមទារ៖ ត្រង់ចំណុចនេះ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ចាំបាច់ត្រូវសរសេរឱ្យបានដាក់ច្បាស់ និងចំៗ ពីខ្លឹមសារនៃសាលក្រម ដែលដើមចោទធ្វើការទាមទារឱ្យតុលាការចេញតាមការចង់បានរបស់ខ្លួន ដោយផ្អែកលើទំហំនៃការខាតបង់ និងខូចប្រយោជន៍ ដែលបណ្ដាលមកពីវិវាទដែលបានកើតឡើង ដោយសកម្មភាពភាគីម្ខាងទៀត។[7]
- មូលហេតុនៃការទាមទារ៖ ដោយឡែក ចំពោះចំណុចនេះវិញ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ត្រូវធ្វើការសរសេររៀបរាប់ជាចាំបាច់អង្គហេតុសំខាន់ៗ ដើម្បីបញ្ជាក់ពីមូលហេតុនៃការទាមទាររបស់ខ្លួនដែរ ព្រោះថាកាលណាការសរសេរអង្គហេតុបានក្បោះក្បាយត្រឹមត្រូវ និងសមហេតុផលល្អនោះ វានឹងជាកាតាលីករជម្រុញឱ្យយើងមានឱកាសឈ្នះក្ដីក៏កាន់តែខ្ពស់ដែរ។[8]

**២. ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្ដឹង**

ក្រៅពីចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង ដូចដែលបានរៀបរាប់ខាងលើរួចមកហើយនោះ យើងក៏នឹងមានការបង្ហាញពីអ្វីដែលគួរគប្បីសរសេរលើចំណុចមូលហេតុនៃការទាមទារ ក្នុងពាក្យបណ្ដឹងនោះដែរ ដែលមានដូចជា៖

- អង្គហេតុនៃការបង្កើតសិទ្ធិ៖ គឺជាអង្គហេតុដែលត្រូវរៀបរាប់ពីមូលហេតុដែលនាំឱ្យមានការបង្កើតសិទ្ធិ ពោលគឺវាជាលំនាំបញ្ហា ដែលនាំឱ្យមានវិវាទរវាងភាគីកើតមានឡើង ឧទាហរណ៍ កិច្ចសន្យាខ្ចីប្រាក់ចំនួន៥០.០០០ដុល្លារ។ ត្រង់ចំណុចនេះយើងគួរគប្បីសរសេរយ៉ាងណា ឱ្យមានភាពក្បោះក្បាយ ត្រឹមត្រូវ សមហេតុផល ទៅតាមអង្គហេតុដែលបានកើតឡើង ព្រោះថា វាគឺជាអង្គហេតុសំខាន់ ដែលនឹងនាំឱ្យមានអង្គហេតុផ្សេងៗ ទៀតកើតមានឡើង

[7] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៧៥ (របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) កថាខណ្ឌទី២ ចំណុច(ខ)។

[8] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៧៥ (របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) កថាខណ្ឌទី៣។

- អង្គហេតុបង្កើតឧបសគ្គនៃការកកើតសិទ្ធិ៖ ជាអង្គហេតុ ឬមូលហេតុ ដែលនាំឱ្យមានការចាប់ផ្តើមនៃវិវាទកើតមានឡើង ដោយភាគីណាម្ខាងមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ដែលមានចែងក្នុងកិច្ចសន្យា និងជាមូលហេតុដែលនាំឱ្យកិច្ចសន្យាមានវិការៈ ឧទាហរណ៍ លោក ខ បានខ្ចីប្រាក់៥០.០០០ ដុល្លារ ពីលោក ក បន្ទាប់មក លោក ខ មិនបានអនុវត្តកាតព្វកិច្ច ដោយសងជាប្រាក់ ឬបង់ការប្រាក់ជូនទៅឱ្យលោក ក វិញឡើយ។ នេះគឺជាអង្គហេតុសំខាន់ ដែលវាជាភស្តុតាងដាក់បន្ទុកលើភាគីចុងចម្លើយ និងជាអង្គហេតុដែលជួយយើងក្នុងដំណាក់កាលសវនាការបានដែរ។
- អង្គហេតុនាំឱ្យមានការរំលត់សិទ្ធិ៖ ចំពោះចំណុចនេះវិញ គឺជាអង្គហេតុតវ៉ារបស់ចុងចម្លើយលើការចោទប្រកាន់របស់ដើមចោទ ដែលអះអាងពីការរលត់កាតព្វកិច្ចរបស់ខ្លួន និងការរំលត់សិទ្ធិរបស់ដើមចោទក្នុងកិច្ចសន្យា ឧទាហរណ៍ លោក ខ អះអាងថាបានសងប្រាក់៥០.០០០ដុល្លារ ឬក៏បានសងជាការប្រាក់គ្រប់ចំនួនទៅលោក ក រួចហើយ ប៉ុន្តែលោក ក នៅតែទាមទារឱ្យលោក ខ អនុវត្តកាតព្វកិច្ចជាបន្តទៀត។ ត្រង់ចំណុចនេះ អាចជាប្រយោជន៍ដល់ចុងចម្លើយ ប៉ុន្តែដើមបណ្តឹង ឬអ្នកដាក់ពាក្យបណ្តឹងអាចសរសេរ ឬយកចំណុចនេះជាឱកាសក្នុងការយកលេស ឬហេតុផលមិនសមរម្យក្នុងការលើកឡើងរបស់ចុងចម្លើយបាន។
- អង្គហេតុបង្កើតការរារាំងការអនុវត្តសិទ្ធិ៖ ត្រង់ចំណុចនេះស្រដៀងនឹងអង្គហេតុខាងលើដែរ វាគឺជាការអះអាងពីការតវ៉ារបស់ចុងចម្លើយក្នុងការមិនព្រមអនុវត្តកាតព្វកិច្ចខ្លួន ដោយស្ថិតក្រោមហេតុផលណាមួយ ឧទាហរណ៍ លោក ខ អះអាងថានឹងសងប្រាក់៥០.០០០ដុល្លារ ទៅលោក ក នៅពេលដែលដល់ពេលកំណត់ ប៉ុន្តែពេលកំណត់មិនទាន់មកដល់ លោក ក បានអនុវត្តសិទ្ធិទាមទារប្រាក់មកវិញ ដែលជាហេតុនាំឱ្យលោក ខ បានរារាំងការអនុវត្តសិទ្ធិរបស់លោក ក។ អង្គហេតុនេះ ក៏អាចជាប្រយោជន៍ដល់ចុងចម្លើយបានដែរ ប៉ុន្តែដើមបណ្តឹង ឬអ្នកដាក់ពាក្យបណ្តឹងអាចសរសេរ ឬយកចំណុចនេះជាឱកាសក្នុងការយកលេស ឬហេតុផលមិនសមរម្យរបស់ចុងចម្លើយបាន។

## កថាខណ្ឌទី២៖ ប្រភេទនៃបណ្តឹងរដ្ឋប្បវេណី

បណ្តឹងអាចនឹងមានច្រើនប្រភេទ ទៅតាមបទដ្ឋាននីមួយៗ ដោយឡែក បើយើងងាកមកមើលប្រភេទនៃបណ្តឹងរដ្ឋប្បវេណីវិញ យើងឃើញថា បណ្តឹងរដ្ឋប្បវេណីជាប្រភេទបណ្តឹងមួយ ដែលជាកម្មវត្ថុទាមទារលើការចង់បានរបស់ភាគី ហើយកម្មវត្ថុនៅក្នុងបណ្តឹងរដ្ឋប្បវេណីមានច្រើនប្រភេទ ដោយផ្អែកតាមអំពើនៃបទល្មើសនោះ ដូច្នេះ ថាតើគេអាចធ្វើការបែងចែកប្រភេទនៃបណ្តឹងរដ្ឋប្បវេណីតាមរបៀបយ៉ាងដូចម្តេច? ប្រភេទបណ្តឹងរដ្ឋប្បវេណីត្រូវបានគេបែងចែក ដោយផ្អែកតាមប្រភេទ និងបែបយ៉ាងនៃកម្មវត្ថុលើការទាមទារតាមផ្លូវបណ្តឹង មកធ្វើជាបទដ្ឋានក្នុងការបែងចែកប្រភេទនៃបណ្តឹងរដ្ឋប្បវេណី រួមមានដូចជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក(១)

បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត(២) បណ្ដឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត(៣)។[9]

**១. បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក**

បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក ជាធម្មតាត្រូវបានគេឱ្យនិយមន័យថា ជាបណ្ដឹងដែលធ្វើការទាមទារឱ្យតុលាការចេញសាលក្រមតាមការទាមទាររបស់ខ្លួន ដោយបង្គាប់ឱ្យចុងចម្លើយផ្ដល់តាវកាលិកស្របតាមការទាមទារ ដោយផ្អែកលើអត្ថិភាពនៃសិទ្ធិដែលខ្លួនមាន ក្នុងការទាមទារស្របតាមច្បាប់សារធាតុដែលបានកំណត់គឺក្រមរដ្ឋប្បវេណី។[10] នេះបើយោងតាមសន្ធានុក្រម ផ្នែករដ្ឋប្បវេណី *តាវកាលិក គឺជាវត្ថុ ឬសកម្មភាព ដែលជាទីតាំង (ឬជាកម្មវត្ថុ) នៃកាតព្វកិច្ច។* ដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា បណ្ដឹងដែលធ្វើការទាមទារឱ្យផ្ដល់តាវកាលិក គឺជាប្រភេទបណ្ដឹងដែលទាមទារទៅលើ៖

- សកម្មភាពនៃការទាមទារឱ្យបង់ជាប្រាក់
- សកម្មភាពនៃការទាមទារឱ្យធ្វើតាមឆន្ទៈ ឬមិនឱ្យធ្វើសកម្មភាពណាមួយ
- ការទាមទារឱ្យប្រគល់អចលនទ្រព្យដូចជាផ្ទះសម្បែង ដីធ្លី សំណង់អគារផ្សេងៗ
- ការទាមទារឱ្យប្រគល់ចលនទ្រព្យដូចជារថយន្ត សម្ភារៈផ្សេងៗជាដើម។

**២. បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត**

បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺជាប្រភេទបណ្ដឹងដែលសុំធ្វើការទាមទារឱ្យតុលាការប្រកាសសាលក្រម ចំពោះទំនាក់ទំនងគតិយុត្តថ្មី រវាងភាគីដើមចោទ និងចុងចម្លើយពីការបង្កើត ផ្លាស់ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តចាស់ ដោយផ្អែកលើការអះអាងពីអត្ថិភាពនៃសិទ្ធិ ក្នុងការទាមទារតាមផ្លូវបណ្ដឹង។[11] ហើយបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ជាប្រភេទបណ្ដឹងដែលកើតមានជាច្រើនករណីក្នុងសង្គមរបស់យើងសព្វថ្ងៃ និងបានក្លាយជារឿងធម្មតាបាត់ទៅហើយ ដែលករណីទាំងនោះមានដូចខាងក្រោម៖

---

[9] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកការរៀបចំសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី *សេចក្ដីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម* ផ្នែកទី៣ ប្រភេទនៃបណ្ដឹង ទំព័រ៤៥។

[10] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកការរៀបចំសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី *សេចក្ដីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម* កថាភាគទី១ បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក ទំព័រ៤៥។

[11] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកការរៀបចំសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី *សេចក្ដីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម* កថាភាគទី ៣ បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ទំព័រ៥០។

- បណ្ដឹងអំពីការសុំលែងលះ៖ ដែលបណ្ដឹងប្រភេទនេះ ជាបណ្ដឹងដែលសុំឱ្យតុលាការ ធ្វើការចេញសាលក្រម ដើម្បីរំលត់ទំនាក់ទំនងគតិយុត្ត គឺការរំលត់ ឬបញ្ចប់ចំណងអាពាហ៍ពិពាហ៍រវាងភាគីដើមចោទ និងភាគីចុងចម្លើយ។ ការលែងលះគ្នារវាងប្ដីប្រពន្ធមិនអាចចេះតែសម្រេចដោយឯកឯងបាននោះទេ បើទោះបីជាប្ដីប្រពន្ធសម្រេចចិត្តរស់នៅផ្សេងគ្នា ឬឆ្ងាយពីគ្នាក៏ដោយ ក៏ចំណងអាពាហ៍ពិពាហ៍ ដែលបានទទួលស្គាល់ដោយច្បាប់ នៅតែមិនមានការផុតរលត់ដដែល ហើយប្ដី ឬប្រពន្ធនោះ មិនអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្ដងទៀតបាននោះទេ លុះត្រាតែមានការសម្រេចបញ្ចប់ចំណងអាពាហ៍ពិពាហ៍ចាស់ដោយសាលក្រមរបស់តុលាការជាមុនសិន។ ឧទាហរណ៍ លោក ក បានដាក់ពាក្យបណ្ដឹងលែងលះនឹងប្រពន្ធរបស់គាត់ គឺអ្នកស្រី ខ ទៅកាន់តុលាការ ដោយសុំឱ្យតុលាការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ រវាងពួកគាត់ទាំងពីរ។
- បណ្ដឹងអំពីការសុំកូន៖ បណ្ដឹងប្រភេទនេះ ក៏ជាបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តដែរ ព្រោះបណ្ដឹងពីការសុំកូននេះ គឺជាបណ្ដឹងដែលសុំឱ្យតុលាការចេញសាលក្រម ដើម្បីបង្កើតទំនាក់ទំនងគតិយុត្តថ្មី គឺពីការសុំកូនអ្នកដទៃ ឱ្យប្រែក្លាយជាកូនស្របច្បាប់របស់ខ្លួន ដោយមានសិទ្ធិ និងកាតព្វកិច្ចដូចនឹងឪពុកម្ដាយបង្កើត។ ការសុំកូនគេមកចិញ្ចឹមក៏ត្រូវឆ្លងកាត់ និងមានការយល់ព្រមពីតុលាការដែរ បើតុលាការយល់ឃើញថា សមហេតុផល ឬសមរម្យត្រឹមត្រូវ នោះតុលាការនឹងចេញសាលក្រម ឱ្យភាគីដែលទាមទារ ក្លាយជាឪពុកម្ដាយស្របតាមច្បាប់ ប៉ុន្តែបើក្នុងករណីភាគីមានបំណងមិនល្អ តុលាការនឹងមិនចេញសាលក្រមឱ្យនោះទេ ព្រោះមានករណីច្រើនកន្លងមកហើយ ដែលមានជនខិលខូចមួយចំនួន សុំកូនដើម្បីយកទៅប្រើប្រាស់ ឬផលប្រយោជន៍ផ្សេង។ ឧទាហរណ៍ លោក ក និងអ្នកស្រី ខ បានស្នើសុំឱ្យតុលាការបង្កើតទំនាក់ទំនងគតិយុត្តជាឪពុកម្ដាយស្របច្បាប់របស់ក្មេងប្រុសម្នាក់ ដោយហេតុថា ក្មេងប្រុសនោះកំព្រា និងមិនអាចផ្គត់ផ្គង់ការរស់នៅដោយខ្លួនឯងបាន។

**៣. បណ្ដឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត**

បណ្ដឹងប្រភេទនេះ គឺជាបណ្ដឹងដែលធ្វើការសុំទាមទារឱ្យតុលាការចេញសាលក្រមអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយ ដែលការទាមទារនោះត្រូវបានអះអាងដោយដើមបណ្ដឹងរដ្ឋប្បវេណី អំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃការទាមទារក្នុងបណ្ដឹង។ សម្រាប់បណ្ដឹងដែលទាមទារឱ្យបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្តនេះ គឺមានលក្ខណៈងាយស្រួលក្នុងការយល់ជាងបណ្ដឹង២ប្រភេទខាងលើ ព្រោះថាគោលបំណងនៃបណ្ដឹងនេះ គ្រាន់តែជាបណ្ដឹងដែលសុំឱ្យតុលារការបញ្ជាក់ ឬទទួលស្គាល់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលខ្លួនកំពុងមានស្រាប់ ឬក៏ជាការសុំឱ្យតុលារការបដិសេធ ឬមិនទទួលស្គាល់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលភាគីចុងចម្លើយកំពុងកាន់កាប់។

## ផ្នែកទី២៖ ភាគីបណ្តឹងរដ្ឋប្បវេណី

ភាគីបណ្តឹងនៅក្នុងរឿងក្តីរដ្ឋប្បវេណីមាន២គឺ ភាគីខាងដើមចោទ(ដើមបណ្តឹងរដ្ឋប្បវេណី) និង ភាគីខាងចុងចម្លើយ ដែលភាគីខាងដើមចោទ គឺជាភាគីដែលស្នើសុំឱ្យតុលាការធ្វើការចេញសាលក្រមដែលមានអត្ថន័យស្របតាមការទាមទារ និងការចង់បានរបស់ខ្លួនទៅលើភាគីចុងចម្លើយ ដោយអះអាងពីអត្ថិភាពនៃសិទ្ធិស្របច្បាប់របស់ខ្លួន រីឯភាគីខាងចុងចម្លើយវិញ ជាភាគីដែលមានសិទ្ធិអះអាង ឬតវ៉ាលើការទាមទាររបស់ភាគីខាងដើមចោទ ដោយផ្អែកលើអង្គហេតុ និងភស្តុតាងស្របច្បាប់របស់ខ្លួនដូចគ្នា។ ដោយភាគីទាំង២ គឺជាសមាសភាពដែលនាំឱ្យមានវិវាទតាមផ្លូវច្បាប់កើតមានឡើង ពោលគឺមកពីមូលហេតុនៃភាគីណាម្ខាងមិនបានធ្វើការអនុវត្តកាតព្វកិច្ចបានត្រឹមត្រូវ ដែលជាមូលហេតុនាំឱ្យមានការឈ្លោះទាស់ទែងគ្នា រហូតឈានដល់ដំណាក់កាលនៃការប្តឹងផ្តល់ទៅតុលាការ ដើម្បីទទួលបានការកាត់ក្តីយុត្តិធម៌មួយ ចំពោះវិវាទដែលកើតមានឡើង។

ប៉ុន្តែមានករណីមួយចំនួនដែលរូបវន្តបុគ្គល ឬបុគ្គលឯកជន នឹងមិនអាចក្លាយជាភាគីបណ្តឹងនៅក្នុងរឿងក្តីរដ្ឋប្បវេណីបាន ទោះបីជាភាគីបុគ្គលនោះត្រូវបានទទួលការខូចប្រយោជន៍ដោយសារបុគ្គលម្ខាងទៀតក្តី ក៏បុគ្គលដែលខូច ឬខាតបង់ប្រយោជន៍នោះ មិនអាចក្លាយជាភាគីបណ្តឹង ឬដាក់ពាក្យបណ្តឹងទៅកាន់តុលាការបានឡើយ ផ្ទុយទៅវិញបើបុគ្គលនោះ ធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងផ្ទាល់ នោះតុលាការនឹងធ្វើការច្រាលចោលបណ្តឹងនោះភ្លាម។ ដូច្នេះដើម្បីទទួលបានចំណេះដឹងបន្ថែមអំពី ថាតើប្រភេទបុគ្គលណាខ្លះ ដែលគ្រប់លក្ខណៈសម្បត្តិក្នុងការធ្វើបណ្តឹង យើងគួរស្វែងយល់ពីសមត្ថភាពភាគី(កថាខណ្ឌទី១) និងអ្នកតំណាងតាមផ្លូវបណ្តឹង(កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ សមត្ថភាពភាគី

សមត្ថភាពភាគី គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើការយល់ដឹង ព្រោះថាបើយើងយល់ច្បាស់ពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ទូទៅរបស់បុគ្គល នោះមានន័យថា យើងនឹងមានភាពងាយស្រួលក្នុងការកំណត់ពីបុគ្គលដែលអាចធ្វើបណ្តឹងបាន ឬមិនអាចក្លាយជាភាគីក្នុងបណ្តឹងបាន។ ដោយឡែក ច្បាប់រដ្ឋប្បវេណីនៃប្រទេសកម្ពុជាយើង បានកំណត់ថា រូបវន្តបុគ្គល និងនីតិបុគ្គល ក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ដែលមានន័យថា រូបវន្តបុគ្គល និងនីតិបុគ្គល គឺជាភាគីដែលមានសមត្ថភាព និងសូម្បីតែទារកក្នុងគភ៌ ក៏អាចក្លាយជាភាគី ដែលមានសមត្ថភាពនៅក្នុងរឿងក្តីបណ្តឹងរដ្ឋប្បវេណីបានដែរ។[12] ប៉ុន្តែនៅក្នុងករណីនេះ មិនមែនគ្រប់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលជាភាគីមានសមត្ថភាព សុទ្ធតែអាចមានសមត្ថភាពក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីបានទាំងអស់នោះទេ នៅត្រង់ចំណុចនេះ យើងត្រូវបែងចែកឱ្យបានច្បាស់លាស់ពីពាក្យថា ភាគីមានសមត្ថភាព និងភាគីមាន

[12] ក្រមរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ០៨ ធ្នូ ២០០៧ មាត្រា៦ (គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ) មាត្រា៤៦ (និយមន័យ ប្រភេទ និងគោលការណ៍នៃការបង្កើតនីតិបុគ្គល) កថាខណ្ឌទី១ និងមាត្រា៩ (ទារកនៅក្នុងគភ៌)។

សមត្ថភាពក្នុងការធ្វើបណ្តឹង ឧទាហរណ៍ ទារកក្នុងគភ៌ អាចក្លាយជាភាគី ដែលមានសមត្ថភាពបាន ប៉ុន្តែទារកក្នុងគភ៌ មិនអាចក្លាយជាភាគី ដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងបានទេ។

ច្បាប់បានអនុញ្ញាតឱ្យបុគ្គល ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគិត ពិចារណា និងវិនិច្ឆ័យបានត្រឹមត្រូវប៉ុណ្ណោះ ទើបអាចធ្វើបណ្តឹងបាន និងមិនអនុញ្ញាតឡើយចំពោះបុគ្គលដែលមិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការគិតពិចារណា ដែលមានគោលបំណង គឺដើម្បីការពារផលប្រយោជន៍របស់ជន ដែលមិនទាន់មានការពិចារណាគ្រប់ជ្រុងជ្រោយនោះ កុំឱ្យជនឆ្លៀតឱកាសមួយចំនួនមករំលោភបំពានលើផលប្រយោជន៍របស់ពួកគេបាន។

ដូច្នេះហើយទើបមានចំណុចមួយចំនួន ដែលនឹងត្រូវសិក្សាស្វែងយល់លើបញ្ហាទាំងអស់នេះ ដែលមានដូចជាភាគីមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹង(១) និងករណីកង្វះសមត្ថភាពក្នុងការធ្វើបណ្តឹង(២)។

### ១. ភាគីដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹង

ភាគីដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹងបាន គឺត្រូវបានកំណត់ដោយច្បាប់ បើក្នុងករណីតុលាការរកឃើញថា ភាគីណាម្ខាង ឬទាំងសងខាងខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង នោះតុលាការនឹងចេញសាលក្រមអំពីការលើកបណ្តឹងនោះចោលភ្លាម ដោយមូលហេតុថាផ្ទុយនឹងច្បាប់ និងមានមោឃភាពចាប់តាំងពីថ្ងៃដាក់ពាក្យបណ្តឹងដំបូងមកម្ល៉េះ។ ដូច្នេះហើយ ដើម្បីជៀសវាងកំហុសដោយអចេតនាទាំងអស់នេះ យើងត្រូវសិក្សា ថាតើជនណាខ្លះដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើបណ្តឹង ដែលរួមមានដូចខាងក្រោម៖

- អនីតិជន៖ នេះបើយោងតាមសន្ធានុក្រម ផ្នែករដ្ឋប្បវេណី បានឱ្យនិយមន័យលើពាក្យ អនីតិជន ថា *ជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម១៨ឆ្នាំ* មានន័យថា បុគ្គលដែលមានអាយុជាមធ្យមក្រោម១៨ឆ្នាំ គឺជាបុគ្គលដែលច្បាប់មិនអនុញ្ញាតឱ្យមានសមត្ថភាពក្នុងការធ្វើបណ្តឹងបាននោះទេ ក្រោមហេតុផលថា ជនដែលស្ថិតក្រោម១៨ឆ្នាំនេះ គឺមិនអាចមានគំនិតពិចារណាគ្រប់គ្រាន់ ក្នុងការការពារផលប្រយោជន៍របស់ខ្លួនបានឡើយ ដោយងាយនឹងចាញ់បោកជនឆក់ឱកាសមួយចំនួន។
- ជនដែលស្ថិតក្រោមអាណាព្យាបាល៖ គឺជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឳពុកម្តាយជាទូទៅ ឬស្ថិតក្រោមការមើលថែរបស់សាច់ញាតិនៃជននោះ ដោយជនរូបនេះមានលក្ខណៈស្រដៀងទៅនឹងអនីតិជនដែរ ប៉ុន្តែខុសត្រង់អនីតិជនមួយចំនួន គឺមិនបានស្ថិតក្រោមអាណាព្យាបាលទេ ហើយច្បាប់ក៏មិនបានឱ្យជាមាត្រា ឬនិយមន័យពាក់ព័ន្ធនឹងជន ដែលស្ថិតក្រោមអាណាព្យាបាលនេះដែរ ពោលគឺ មនុស្សទូទៅយល់ឃើញថា វាមិនមានភាព ឬលក្ខណៈចាំបាច់ ដោយផ្អែកលើមូលហេតុ ជនប្រភេទនេះមានលក្ខណៈដូច ឬស្រដៀងទៅនឹងអនីតិជនដែរ។

- ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ៖ គឺជាជនដែលមានបញ្ហាបញ្ញា និងស្មារតីដែលជាទូទៅបុគ្គលប្រភេទនេះត្រូវបានគេសន្មតថាមិនអាចធ្វើការព្យាបាល ឬជាសះស្បើយជារៀងរហូត ដែលជននោះផ្ទាល់ត្រូវមានការសម្រេចចេញសាលក្រមពីតុលាការ ពីការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅនៅពេលវ័យនៃអាយុ១៥ឆ្នាំមកដល់ តាមពាក្យស្នើសុំរបស់ជននោះ[13]។ ដោយផ្អែកលើបញ្ហាបញ្ញា និងស្មារតីជានិរន្តរ៍របស់ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅនេះ ច្បាប់មិនអាចអនុញ្ញាតឱ្យជននោះធ្វើបណ្តឹងដោយខ្លួនឯងបានឡើយ ជៀសវាងនាំឱ្យមានការខូចផលប្រយោជន៍របស់ជននោះបាន។
- ជនដែលស្ថិតក្រោមហិតូបត្ថម្ភ៖ ជនដែលត្រូវបានកម្រិតសមត្ថភាពមួយនេះវិញ គឺជាបុគ្គលដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹងពីច្បាប់ ដោយសារមានបញ្ហាបញ្ញា និងស្មារតីមិនគ្រប់គ្រាន់ដើម្បីវិនិច្ឆ័យពីអំពើដែលបង្កឡើងដោយសកម្មភាពរបស់ខ្លួន។[14] ដោយជនរូបនេះខុសពីជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅត្រង់ថា ជនដែលស្ថិតក្រោមហិតូបត្ថម្ភ មានបញ្ញាស្មារតី គ្រាន់បើជាងជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដែលផ្អែកបញ្ញា និងស្មារតីអាចមិនជាសះស្បើយជារៀងរហូត ទោះបីជាយ៉ាងណា ច្បាប់ក៏នៅតែមិនអាចអនុញ្ញាតឱ្យជននោះធ្វើបណ្តឹងដោយខ្លួនឯងបានឡើយ ជៀសវាងនាំឱ្យខូចប្រយោជន៍ដល់ជននោះបាន។

សរុបជារួមមក ជនដូចដែលបានរៀបរាប់ខាងលើ ដែលមានដូចជាអនីតិជន ជនដែលស្ថិតនៅក្រោមអាណាព្យាបាល ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជនដែលស្ថិតក្រោមហិតូបត្ថម្ភ គឺសុទ្ធសឹងតែមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីបានដោយឯកឯងនោះទេ ពោលគឺ ច្បាប់មានចេតនាក្នុងការការពារផលប្រយោជន៍របស់ជនទាំងអស់នោះ រហូតដល់ពេលពួកគេមានសមត្ថភាពក្នុងការធ្វើបណ្តឹងឡើងវិញ ឬចាំរហូតដល់ពួកគេមានជំនួយពីតតិយជនដែលច្បាប់បានអនុញ្ញាត ទើបដំណើរការនៃការធ្វើបណ្តឹងមានលក្ខណៈត្រឹមត្រូវ និងស្របតាមច្បាប់។

**២. ករណីកង្វះសមត្ថភាពក្នុងការធ្វើបណ្តឹង**

ក្នុងករណីដែលបុគ្គលត្រូវបានគេកម្រិតសមត្ថភាពខាងលើនោះ បានជួបប្រទះបញ្ហាដែលនាំឱ្យពួកគេខូចផលប្រយោជន៍ភ្លាមៗ តើច្បាប់នឹងចូលខ្លួនដើរតួការពារពួកគេ ពីការខូចប្រយោជន៍ទាំងអស់នោះយ៉ាងដូចម្តេចទៅវិញ? អ្នកបង្កើតច្បាប់ បានបង្កើតច្បាប់ឡើងដោយមិនមានលក្ខណៈតឹងតែងរហូតដល់ថ្នាក់គ្មានផ្លូវទុក

[13] ក្រមរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ០៨ ធ្នូ ២០០៧ មាត្រា២៤ (ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) កថាខណ្ឌទី១។

[14] ក្រមរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ០៨ ធ្នូ ២០០៧ មាត្រា២៨ (ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ) កថាខណ្ឌទី១។

សម្រាប់ដោះស្រាយសោះនោះទេ ពោលគឺច្បាប់តែងទុកចន្លោះមួយសម្រាប់បុគ្គលដែលអនុវត្តច្បាប់នោះឱ្យមានឱកាសក្នុងការជួយទៅដល់ជនរងគ្រោះ ដែលត្រូវការជំនួយបន្ទាន់ដើម្បីជៀសវាងការខាតបង់ប្រយោជន៍របស់ពួកគេ ដោយសារតែហេតុថាច្បាប់មានលក្ខណៈតឹងតែងពេក។ ចំពោះក្រមនៃនីតិវិធីរដ្ឋប្បវេណីក៏ដូចគ្នា ដោយក្រមនេះបានទុកចន្លោះឱ្យបុគ្គលដែលត្រូវបានគេកម្រិតសមត្ថភាព ឱ្យមានឱកាសចូលខ្លួនដើម្បីទទួលបានការការពារផលប្រយោជន៍ក្នុងពេលបន្ទាន់តាមផ្លូវបណ្ដឹងបានដែរ ដោយអនុវត្តក្រោមលក្ខខណ្ឌមួយចំនួនដូចខាងក្រោមនេះ៖

- ការទុកពេលឱ្យកែតម្រូវ៖ បើតុលាការរកឃើញថា ភាគីខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ក្នុងការការពារអសមត្ថជននោះ តុលាការមិនធ្វើការបដិសេធបណ្ដឹងនោះភ្លាមៗទេ ពោលគឺតុលាការនឹងទុកពេលយ៉ាងសមរម្យមួយ ដើម្បីឱ្យភាគីធ្វើការកែតម្រូវត្រង់ចំណុចដែលខ្វះខាត ឬផ្ទុយទៅនឹងច្បាប់នោះ
- ការអនុវត្តបណ្ដឹងជាបណ្ដោះអាសន្ន៖ តុលាការអាចនឹងធ្វើការអនុញ្ញាតឱ្យបុគ្គល ដែលត្រូវបានកម្រិតសមត្ថភាព ធ្វើសកម្មភាពបណ្ដឹងជាបណ្ដោះអាសន្នបាន បើមានការបង្កឱ្យខូចប្រយោជន៍របស់ជននោះក្នុងពេលបន្ទាន់ ឬដោយសារការយឺតយ៉ាវណាមួយក្នុងពេលធ្វើបណ្ដឹង
- ការចូលខ្លួនការពាររបស់ភាគីមានសមត្ថភាព៖ បើមានភាគីមានសមត្ថភាពធ្វើបណ្ដឹង ឬអាណាព្យាបាល ឬអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈ ឬអ្នកតំណាងដែលច្បាប់បានកំណត់ បានចូលខ្លួនមកការពារ និងដោះស្រាយជូនបុគ្គលដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្ដឹងនោះ ក្នុងរយៈពេលសមរម្យណាមួយ នាំឱ្យបណ្ដឹងដែលបុគ្គលនោះទាមទារឱ្យតុលាការជួយធ្វើការដោះស្រាយ នឹងមានអានុភាពប្រតិសកម្មចាប់តាំងពីពេលដែលបណ្ដឹងនោះបានធ្វើឡើង។[15]

**កថាខណ្ឌទី២៖ អ្នកតំណាងតាមផ្លូវបណ្ដឹង**

ចំពោះពាក្យអ្នកតំណាងតាមផ្លូវបណ្ដឹងនេះ ជាទូទៅត្រូវបានគេឱ្យនិយមន័យថា ជាសកម្មភាពរបស់ភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ដើម្បីទទួល ឬជំនួសសកម្មភាពបណ្ដឹងរបស់ភាគីក្នុងបណ្ដឹង(សំដៅទៅលើភាគីខាងដើមចោទ ឬភាគីខាងចុងចម្លើយ) ដោយផ្អែកតាមការសម្រេចចិត្តតាមឆន្ទៈរបស់ខ្លួន ឬដោយស្ម័គ្រចិត្ត ឬក៏អាចជាកាតព្វកិច្ច ដែលត្រូវទទួលជំនួសឱ្យភាគីកង្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ដើម្បីធ្វើការផ្ដល់ការការពារលើផលប្រយោជន៍របស់ពួកគេ។ អ្នកតំណាងតាមផ្លូវបណ្ដឹង ជាទូទៅ ត្រូវបានច្បាប់ធ្វើការបែងចែកជា២ប្រភេទ គឺអ្នកតំណាងដែលច្បាប់បានកំណត់(១) និងអ្នកតំណាងដោយអាណត្តិ(២)។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៥ (វិធានការណ៍ក្នុងករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹងជាអាទិ៍) កថាខណ្ឌទី១ និងកថាខណ្ឌទី២។

### ១. អ្នកតំណាងដែលច្បាប់បានកំណត់

អ្នកតំណាងដែលច្បាប់បានកំណត់ គឺជាអ្នកតំណាងដែលទទួលស្គាល់ដោយច្បាប់ ឬប្រកាសចេញដោយសាលក្រមរបស់តុលាការ ដែលអ្នកតំណាងនោះមានសិទ្ធិលើភាគី ដែលស្ថិតក្រោមការតំណាងរបស់ខ្លួនទៅតាមអ្វីដែលច្បាប់បានកំណត់ និងមានសិទ្ធិធ្វើបណ្តឹងជំនួសឱ្យភាគីបានដែរ ក្នុងគោលបំណងការពារផលប្រយោជន៍របស់ភាគីនោះ។ ដែលជាទូទៅភាគីដែលស្ថិតក្រោមការតំណាងនោះ អសមត្ថភាពក្នុងការធ្វើបណ្តឹងដោយខ្លួនឯង ដូច្នេះហើយទើបច្បាប់បានអនុញ្ញាតឱ្យមានអ្នកតំណាង ដើរតួជាអ្នកការពារជនទាំងអស់នោះ ហើយអ្នកតំណាងដែលច្បាប់បានកំណត់នោះ នឹងធ្វើការពន្យល់រៀបរាប់ដូចខាងក្រោម៖

- អាណាព្យាបាល៖ អ្នកតំណាងដែលច្បាប់បានកំណត់ប្រភេទនេះ ជាទូទៅ គឺជាឪពុកម្តាយ ឬក៏អាចជាសាច់ញាតិជិតស្និតរបស់អនីតិជន ដែលមើលថែ និងទទួលខុសត្រូវក្នុងនាមជាអាណាព្យាបាល បើមានវិវាទរដ្ឋប្បវេណីកើតឡើង ឬក៏ត្រូវដោះស្រាយដែលបង្កឡើងដោយសកម្មភាពរបស់អនីតិជននោះ អាណាព្យាបាលត្រូវចូលខ្លួនការពារជាចាំបាច់។
- អាណាព្យាបាលទូទៅ៖ អ្នកតំណាងដែលច្បាប់បានកំណត់ជាអាណាព្យាបាលទូទៅនេះ កើតឡើងពីការប្រកាសទទួលស្គាល់របស់តុលាការ គឺការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីភាគី ដែលមានអាយុ១៥ឆ្នាំឡើងទៅ ដោយការអះអាងរបស់សាមីភាគីក្រោមមូលហេតុ មានបញ្ហាខាងផ្នែកបញ្ញា ស្មារតី[16] និងដើម្បីការពារពីការរំលោភបំពានសិទ្ធិពីជនឆ្លៀតឱកាស។
- ហិតូបត្ថម្ភកៈ៖ ហិតូបត្ថម្ភកៈ ជាអ្នកតំណាងដែលច្បាប់បានកំណត់ ដែលមានលក្ខណៈស្រដៀងនឹងអាណាព្យាបាលទូទៅដែរ ដោយកើតឡើងពីសេចក្តីប្រកាសរបស់តុលាការ គឺការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់ជននោះ ដោយមូលហេតុនៃការពិចារណា និងការយល់ដឹងទាក់ទងនឹងសកម្មភាពរបស់ខ្លួនតាមផ្លូវច្បាប់ មានសមត្ថភាពតិចតួចពេក[17] ដែលអាចជាមូលហេតុនាំឱ្យបុគ្គលនោះ អាចនឹងត្រូវគេរំលោភលើផលប្រយោជន៍បាន បើគ្មានការការពារពីអ្នកតំណាងដែលច្បាប់បានកំណត់ទេនោះ។
- អ្នកតំណាងពិសេស៖ អ្នកតំណាងដែលច្បាប់បានកំណត់មួយនេះវិញ ត្រូវបានប្រកាស និងប្រគល់ដោយតុលាការផ្ទាល់ សម្រាប់ក្នុងករណីដែលភាគីបណ្តឹងខ្វះសមត្ថភាព និងត្រូវការដំណើរការបណ្តឹង

[16] ក្រមរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ០៨ ធ្នូ ២០០៧ មាត្រា២៤ (ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) កថាខណ្ឌទី១។

[17] ក្រមរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ០៨ ធ្នូ ២០០៧ មាត្រា២៨ (ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ) កថាខណ្ឌទី១។

ជាបន្ទាន់ដើម្បីការពារប្រយោជន៍របស់បុគ្គលនោះ ហើយការជ្រើសតាំងអ្នកតំណាងពិសេសនេះ គឺត្រូវដាក់ពាក្យសុំទៅតុលាការដែលទទួលពាក្យបណ្ដឹងនោះ ដោយសាមីភាគីផ្ទាល់។[18]

**២. អ្នកតំណាងដោយអាណត្តិ**

អ្នកតំណាងដោយអាណត្តិ គឺជាអ្នកតំណាងដែលកើតចេញពីការយល់ព្រម ឬក៏កើតចេញពីឆន្ទៈរបស់ភាគី ដោយផ្ដល់ឱ្យសិទ្ធិក្នុងការធ្វើបណ្ដឹងទៅអ្នកតំណាងនោះ ក្រោមមូលហេតុថា អ្នកតំណាងដោយអាណត្តិមានសមត្ថភាព និងបទពិសោធន៍តាមផ្លូវតុលាការច្រើន ដែលធ្វើឱ្យដំណើរការក្នុងរឿងក្ដីមានភាពរលូន និងឆាប់រហ័សដែរ។ អ្នកតំណាងដោយអាណត្តិ ដែលជាទូទៅត្រូវបានមនុស្សគ្រប់គ្នាស្គាល់ថា ជាមេធាវី និងសូម្បីតែក្រមនៃនីតិវិធីរដ្ឋប្បវេណីក៏បានទទួលស្គាល់យ៉ាងដូច្នេះដែរ គឺត្រង់មាត្រា៥៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ដែលអ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី។

មេធាវី គឺជាអ្នកតំណាង ដែលត្រូវបានជ្រើសរើសផ្អែកតាមឆន្ទៈរបស់កូនក្ដី(ភាគីដើមចោទ ឬភាគីចុងចម្លើយ) សម្រាប់ពឹងពាក់ឱ្យការពារផលប្រយោជន៍ និងដំណើរការរឿងក្ដីឱ្យកាន់តែមានប្រសិទ្ធិភាព ឆាប់រហ័ស និងស្របតាមច្បាប់។ មិនត្រឹមតែប៉ុណ្ណោះ វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈមួយដែលមានភាពឯករាជ្យ និងដោយសេរីក្នុងការចូលខ្លួនបម្រើឱ្យវិស័យតុលាការ និងវិស័យយុត្តិធម៌[19] ហើយមេធាវីខ្លួនឯងផ្ទាល់ ក៏ជាបុគ្គលដែលមានចំណេះ និងជំនាញខាងផ្នែកតុលាការច្បាស់លាស់ ព្រោះថាមេធាវី គឺជាអ្នករៀបចំឯកសារដាក់ពាក្យបណ្ដឹង និងតតាំងដោយផ្ទាល់មាត់នៅក្នុងសវនាការ ដើម្បីរកដំណោះស្រាយ ក៏ដូចជាភាពជោគជ័យជូនកូនក្ដីរបស់ខ្លួន។

សម្រាប់ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិ មិនមែនជាមេធាវី ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីក្រោមលក្ខខណ្ឌមួយចំនួន ដែលមានការកំណត់ដូចខាងក្រោម៖

- រឿងក្ដីក្រោមទឹកប្រាក់ ១.០០០.០០០រៀល៖ តុលាការអនុញ្ញាតឱ្យតតិយជន ក្លាយជាអ្នកតំណាងដោយអាណត្តិបាន ដោយមិនមែនជាមេធាវី
- ការតែងតាំងបុគ្គលិកពីស្ថាប័នរដ្ឋ៖ តុលាការអនុញ្ញាតឱ្យបុគ្គលិកដែលជាតំណាងដោយស្ថាប័នរដ្ឋណាមួយ ក្លាយជាអ្នកតំណាងដោយអាណត្តិបាន ដែលមិនមែនជាមេធាវី
- ការអនុញ្ញាតពីច្បាប់៖ ក្នុងករណីច្បាប់ផ្សេងទៀតអនុញ្ញាតឱ្យមានការតែងតាំងតតិយជន ឱ្យក្លាយជាអ្នកតំណាងដោយអាណត្តិ ឬក្រមនីតិវិធីរដ្ឋប្បវេណីជាដើម ។[20]

[18] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៦ (អ្នកតំណាងពិសេស) កថាខណ្ឌ១។

[19] ច្បាប់ស្ដីលក្ខន្តិកៈមេធាវី ព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ២២ សីហា ១៩៩៥ មាត្រា១។

[20] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៥៣ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) កថាខណ្ឌទី១។

# ជំពូកទី២
# ដំណើរការនីតិវិធីនៃការ
# ជម្រះក្ដីលើកទី១

## ជំពូកទី២៖ ដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១

ដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១ គឺជាជំហានបន្ទាប់នៃជំពូកទី១ ដោយដំណាក់កាលនេះ ជាការរៀបចំ ដើម្បីដំណើរការរឿងក្តីនៅក្នុងសវនាការ ដែលភាគីខាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការជួយធ្វើការដោះស្រាយវិវាទដែលកើតមានឡើង និងក៏ជាឱកាសរបស់ចុងចម្លើយក្នុងការឆ្លើយតតាំងនឹងការចោទប្រកាន់របស់ដើមចោទដែរ ដោយភាគីនីមួយៗ ធ្វើការអះអាងដោយផ្ទាល់មាត់ដោយបញ្ជាក់ពីហេតុផល និងដំណោះស្រាយរៀងៗខ្លួន ដើម្បីការពារផលប្រយោជន៍របស់ពួកគេ។ នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១ ឬដំណើរការនីតិវិធីនៃការជម្រះក្តីនៅសាលាដំបូង ត្រូវបានចែកចេញជា២នីតិវិធីសំខាន់ៗ គឺនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល(ផ្នែកទី១) និងនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់(ផ្នែកទី២)។

### ផ្នែកទី១៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលតុលាការធ្វើការស្តាប់ការបំភ្លឺពីការអះអាងរបស់ភាគីទាំងសងខាងលើចំណុចវិវាទ ដែលភាគីទាំងពីរមិនយល់ស្របគ្នា ហើយតុលាការនឹងយកដំណាក់កាលនេះ ដើម្បីរៀបចំអំពីភាពច្បាស់លាស់នៃចំណុចវិវាទ និងកត់ត្រាទុកភស្តុតាងមួយចំនួនសម្រាប់ដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់បន្តទៀត។[21] បើនិយាយឱ្យស្រួលស្តាប់ជាងនេះ មានន័យថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គ្រាន់តែជានីតិវិធីដែលតុលាការស្តាប់ការអះអាងរបស់ភាគីលើចំណុចវិវាទតែប៉ុណ្ណោះ គឺមិនមានជាការតតាំងដោយផ្ទាល់មាត់របស់ភាគីនោះទេ។ ដូច្នេះមុននឹងចូលទៅកាន់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល យើងគួរស្វែងយល់ពីសំណុំឯកសារត្រៀម(កថាខណ្ឌទី១) និងសកម្មភាពក្នុងពេលដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល(កថាខណ្ឌទី២)។

#### កថាខណ្ឌទី១៖ សំណុំឯកសារត្រៀម

សំណុំឯកសារត្រៀម គឺឯកសារដែលត្រៀមសម្រាប់ចូលទៅកាន់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីធ្វើការបង្ហាញ និងដាក់ជូនទៅកាន់តុលាការអំពីអង្គហេតុនៃចំណុចវិវាទ កម្មវត្ថុនៃការទាមទារ និងមូលហេតុនៃការទាមទាររបស់ភាគី និងសំណុំភស្តុតាងជាឯកសារសំខាន់ផ្សេងៗទៀត ដើម្បីឱ្យតុលាការបានត្រួតពិនិត្យ និងរក្សាទុកឯកសារទាំងអស់នោះសម្រាប់ជាភស្តុតាង ដើម្បីបន្តនីតិវិធីដំណាក់កាលដទៃទៀតបានដែរ ដែលជាទូទៅ នៅក្នុងសំណុំនៃឯកសារត្រៀមនោះមានដូចជាឯកសារត្រៀមសម្រាប់សេចក្តីថ្លែងការណ៍(១) និងភស្តុតាង(២)។

---

[21] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១០៣ (គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)។

**១. ឯកសារត្រៀមសម្រាប់សេចក្ដីថ្លែងការណ៍**

នៅពេលដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការនឹងតម្រូវឱ្យភាគីដាក់ជូនឯកសារត្រៀម ដែលឯកសារនោះត្រូវមានសរសេរពី ៖

- មធ្យោបាយតទល់៖ មានន័យថាភាគីក្នុងបណ្ដឹងគួរសរសេររៀបរាប់ពីវិធីសាស្ត្រនៃការតទល់ ទៅនឹងការទាមទាររបស់ភាគីម្ខាងទៀត ដោយភាគីខាងដើមចោទ គួរសរសេររៀបរាប់ពីការតទល់ទៅនឹងមូលហេតុដែលអះអាងដោយភាគីខាងចុងចម្លើយ ដែលជាមូលហេតុនាំឱ្យមានការរំលត់សិទ្ធិរបស់ខ្លួន
- មធ្យោបាយការពារ៖ មានន័យថាភាគីក្នុងបណ្ដឹងគួរសរសេររៀបរាប់ពីវិធីសាស្ត្រនៃការការពារខ្លួន ពីការចោទប្រកាន់របស់ភាគីម្ខាងទៀត ដោយភាគីខាងចុងចម្លើយ ត្រូវសរសេររៀបរាប់ពីការការពារខ្លួនទាក់ទងនឹងមូលហេតុ ដែលជាការចោទប្រកាន់របស់ភាគីខាងដើមចោទ ដែលបានសរសេរនៅក្នុងពាក្យបណ្ដឹង
- សេចក្ដីថ្លែងការណ៍ពីមធ្យោបាយទាំងនោះ៖ ភាគីក៏ត្រូវត្រៀមបែបបទ និងរបៀបនៅក្នុងការធ្វើសេចក្ដីថ្លែងការណ៍លើមធ្យោបាយតទល់ និងមធ្យោបាយការពាររបស់ខ្លួនដែរ។[22]

**២. ភស្តុតាង**

ភស្តុតាងនៅទីនេះ គឺសំដៅលើភស្តុតាងជាឯកសារ មិនមែនភស្តុតាងជាសាក្សី ឬភស្តុតាងផ្សេងនោះទេ ដោយភស្តុតាងប្រភេទនេះងាយស្រួលដាក់ជូនតុលាការត្រួតពិនិត្យ ដែលជាឧទាហរណ៍មានដូចជាកិច្ចសន្យាខ្ចីប្រាក់ដែលមានស្នាមមេដៃបញ្ជាក់របស់ភាគីនៅលើកិច្ចសន្យា អាចចាត់ទុកជាភស្តុតាងជាឯកសារដើម្បីដាក់ជូនតុលាការត្រួតពិនិត្យបាន។

**កថាខណ្ឌទី២៖ ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រព្រឹត្តទៅបានដោយការកំណត់អំឡុងពេលនៃកាលបរិច្ឆេទណាមួយ ឱ្យបានច្បាស់លាស់ និងសមរម្យដោយតុលាការផ្ទាល់ ដែលកាលបរិច្ឆេទនោះដែរត្រូវស្ថិតក្នុងអំឡុងពេល៣០ថ្ងៃ[23] បន្ទាប់ពីថ្ងៃដែលភាគីបានដាក់ពាក្យបណ្ដឹង ហើយភាគី ឬអ្នកតំណាងនៃភាគីទាំងសងខាងត្រូវមានវត្តមានតាមការកោះហៅរបស់តុលាការ ដើម្បីឱ្យដំណើរការនៃនីតិវិធី អាចប្រព្រឹត្តបានដោយរលូន និងឆាប់រហ័ស។ ដូច្នេះ ដើម្បីឱ្យមានភាពកាន់តែងាយស្រួលក្នុងការស្វែងយល់ត្រង់ចំណុចនេះ យើងបានធ្វើការបែងចែកសកម្មភាពជា២ គឺសកម្មភាពរបស់តុលាការ(១) និងសកម្មភាពរបស់ភាគី(២)។

---

[22] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១០១ (ឯកសារត្រៀម) កថាខណ្ឌទី២។

[23] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៨០ (ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) កថាខណ្ឌទី២។

**១. សកម្មភាពរបស់តុលាការ**

តុលាការ គឺត្រូវបានទទួលអំណាចឯករាជ្យមួយ ដែលអំណាចនេះមានវិសាលភាពអនុវត្តលើគ្រប់រឿងក្តីទាំងអស់ ហើយអំណាចនេះដែរ ត្រូវបានប្រគល់ឱ្យដើម្បីការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូប[24] ដូច្នេះហើយទើបតុលាការត្រូវតែបំពេញតួនាទីរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន និងត្រឹមត្រូវយុត្តិធម៌។ នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការ គឺមានតួនាទីយ៉ាងសកម្ម និងសំខាន់ក្នុងដំណើរការនៃនីតិវិធីមួយនេះ ព្រោះតុលាការត្រូវអនុវត្តតួនាទីតាមអ្វីដែលច្បាប់បានកំណត់ នៅក្នុងអំឡុងពេលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលមានដូចខាងក្រោម៖

- ការផ្សះផ្សា៖ នៅក្នុងរឿងក្តីរដ្ឋប្បវេណីទាំងអស់ បើតុលាការយល់ឃើញថាសមរម្យ នោះដំណាក់កាលនៃការសាកល្បងផ្សះផ្សារវាងភាគីទាំងពីរ នឹងត្រូវលើកឡើងដោយតុលាការ[25] ដោយមិនខ្វល់ថា ការសាកល្បងលើការផ្សះផ្សានោះជោគជ័យ ឬបរាជ័យទេ ព្រោះថាបើការផ្សះផ្សានោះបានផល ភាគីទាំងសងខាងនឹងចំណេញពេលវេលា និងថវិកា ដែលធ្លាប់តែខ្ជះខ្ជាយទៅលើការប្តឹងផ្តល់នេះ
- ការស្នើសុំឱ្យបំភ្លឺអង្គហេតុនៃចំណុចវិវាទ៖ បើការផ្សះផ្សារមិនបានជោគជ័យវិញ នោះតុលាការនឹងបន្តដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយធ្វើការស្នើសុំឱ្យភាគីទាំងពីរ បំភ្លឺអង្គហេតុដែលនាំឱ្យចំណុចវិវាទកើតមានឡើង។ ភាគីដើមបណ្តឹងត្រូវធ្វើសេចក្តីបំភ្លឺអំពីកម្មវត្ថុនៃការទាមទារ និងមូលហេតុដែលនាំឱ្យមានការទាមទារ រីឯភាគីចុងចម្លើយវិញ ត្រូវធ្វើសេចក្តីបំភ្លឺអំពីការឆ្លើយតបនឹងពាក្យបណ្តឹងរបស់ភាគីដើមបណ្តឹង និងមូលហេតុដែលទាមទារឱ្យតុលាការចេញសាលក្រមច្រានចោលការទាមទាររបស់ដើមបណ្តឹង។
- ការស្នើសុំឱ្យដាក់ឯកសារត្រៀម៖ តុលាការនឹងធ្វើការបង្គាប់ឱ្យភាគីនីមួយៗ ដាក់ជូនឯកសារត្រៀមរបស់ខ្លួន ដែលនៅក្នុងឯកសារត្រៀមនោះមានដូចជាមធ្យោបាយតទល់ មធ្យោបាយការពារខ្លួន និងសេចក្តីថ្លែងការណ៍អំពីមធ្យោបាយទាំងនោះ ដែលមានបញ្ញត្តិក្នុងមាត្រា១០១ នៃក្រមរដ្ឋប្បវេណី។
- ការបញ្ជាក់ពីអង្គហេតុដែលត្រូវបំភ្លឺ៖ មុននឹងបញ្ចប់ដំណាក់កាល នៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវប្រកាសបញ្ជាក់ពីអង្គហេតុ ដែលភាគីបានបំភ្លឺកន្លងមក ថាពិតជាត្រឹមត្រូវ និងមិនមានការកែប្រែអ្វីផ្សេងទៀតឡើយ ព្រោះក្រោមមូលហេតុមួយថា អង្គហេតុដែលភាគីបានបំភ្លឺក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ នឹងយកទៅប្រើការបន្តទៀតនាដំណាក់កាលនៃការទាញ

[24] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមគ្មានលេខ ២៤ កញ្ញា ១៩៩៣ មាត្រា១២៨ថ្មី។

[25] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១០៤ (ការសាកល្បងផ្សះផ្សាក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)។

ហេតុផលដោយផ្ទាល់មាត់។[26]

- កំណត់ហេតុ៖ រាល់កំណត់ហេតុ និងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនីមួយៗ ត្រូវបានកត់ត្រាដោយក្រឡាបញ្ជីនៃតុលាការនោះ។[27]

### ២. សកម្មភាពរបស់ភាគី

ក្នុងដំណាក់កាលនៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះដដែល ប៉ុន្តែមិនមែនជាការធ្វើសកម្មភាពរបស់តុលាការដូចមុនទេ ដោយលើកនេះយើងនឹងស្វែងយល់ពីសកម្មភាពរបស់ភាគីវិញម្តង ថាតើភាគីមានសកម្មភាព ឬតួនាទីសំខាន់យ៉ាងដូចម្តេច? ព្រោះថាភាគីបណ្តឹង ក៏ជាផ្នែកមួយដ៏សំខាន់ក្នុងដំណើរការនៃនីតិវិធីមួយនេះដែរ ពោលគឺបើមិនមានវត្តមានរបស់ភាគីបណ្តឹងណាម្ខាងចូលរួមទេ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏មិនអាចប្រព្រឹត្តទៅបានដោយមានភាពរលូននោះដែរ ដូច្នេះសកម្មភាព សិទ្ធិ និងតួនាទីរបស់ភាគី មានដូចចែងខាងក្រោមនេះ៖

- ការមានសិទ្ធិបដិសេធលើការផ្សះផ្សា៖ ភាគីទាំងសងខាង មានសិទ្ធិក្នុងការឆ្លើយបដិសេធលើការផ្សះផ្សា ដែលដាក់ចេញដោយតុលាការបាននៅក្នុងដំណាក់កាលនៃការផ្សះផ្សា ព្រោះថាតុលាការមានសិទ្ធិក្នុងការលើកឡើងដំណាក់កាលនៃការផ្សះផ្សាជូនទៅដល់ភាគីទាំងសងខាងបានដែរ គឺទៅតាមឆន្ទានុសិទ្ធិដែលយល់ឃើញថាសមរម្យ ដូចដែលបានរៀបរាប់ខាងលើ ប៉ុន្តែតុលាការក៏ត្រូវយល់ស្របតាមការសម្រេចចិត្តរបស់ភាគីដែរ ក្នុងករណីដែលភាគីមិនយល់ព្រមលើការផ្សះផ្សានោះ។
- ការថ្លែងការណ៍អំពីអង្គហេតុ៖ ភាគីដើមបណ្តឹងក្តី ឬភាគីចុងចម្លើយក្តី សុទ្ធតែអាចមានសិទ្ធិក្នុងការអះអាងពីវិវាទ ដែលកើតមាននៅក្នុងអង្គហេតុជូនទៅតុលាការដោយលម្អិត ឬដោយសង្ខេបបាន ឬដែលមាននៅក្នុងពាក្យបណ្តឹងស្រាប់ បើយល់ថាចំបាច់ និងមានសារៈសំខាន់សម្រាប់រឿងក្តីរបស់ខ្លួនដែលកំពុងដំណើរការក្នុងនីតិវិធីនេះ។
- ការដាក់ឯកសារត្រៀម៖ ភាគីត្រូវដាក់ឯកសារត្រៀមតាមការបង្គាប់របស់តុលាការ ប៉ុន្តែភាគីផ្ទាល់មានសិទ្ធិក្នុងការដាក់ឯកសារត្រៀមដោយចង់សរសេររៀបរាប់យ៉ាងដូចម្តេចក៏បានដែរ ឱ្យតែការនិយាយរៀបរាប់នៅក្នុងឯកសារត្រៀមនោះជាភស្តុតាងសំខាន់ និងមានតម្លៃ ហើយទាក់ទងនឹងមធ្យោបាយតទល់ មធ្យោបាយការពារខ្លួន ផ្អែកលើហេតុផល និងមូលហេតុសមរម្យស្របតាមច្បាប់។

---

[26] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១០៧ (ការបញ្ជាក់ពីអង្គហេតុដែលនឹងត្រូវបំភ្លឺ ជាអាទិ៍)។

[27] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១០៩ (កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)។

## ផ្នែកទី២៖ ការទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានបញ្ចប់សព្វគ្រប់រួចរាល់អស់ហើយ នីតិវិធីបន្ទាប់ គឺជានីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយនីតិវិធីនេះមានគោលបំណងឱ្យភាគីទាំងសងខាង មានឱកាសក្នុងការអះអាងសេចក្តីថ្លែងការណ៍ដែលខ្លួនបានធ្វើឡើង ដើម្បីការពារផលប្រយោជន៍របស់ពួកគេរៀងៗខ្លួន និងងាយស្រួលសម្រាប់តុលាការក្នុងការវិនិច្ឆ័យស្វែងរកការពិត ដោយស្តាប់ការអះអាងរបស់ភាគី។ ហើយនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ បើអាចត្រូវធ្វើឡើងជាសាធារណៈ ព្រោះថាការជម្រះរឿងក្តីជាសាធារណៈនេះ គឺមានគោលដៅចង់បង្ហាញឱ្យឃើញពីការកាត់ក្តីដោយមានភាពយុត្តិធម៌ ពោលគឺ មិនមានការកាត់ក្តីដោយលាក់កំបាំង ឬជាសម្ងាត់ឡើយ លើកលែងតែក្នុងករណីនៃការជម្រះក្តីជាសាធារណៈនេះ ធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬមានចែងក្នុងច្បាប់ផ្សេងពីការមិនអនុញ្ញាតជាសាធារណៈ[28]។ ការសម្រេចចេញសាលក្រមលើរឿងក្តីមួយដោយតុលាការបាន ចាំបាច់ត្រូវធ្វើឡើងដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[29] ដូច្នេះដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ពីនីតិវិធីនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់នេះ យើងបានធ្វើការបែងចែកចេញជា២សកម្មភាព គឺមុនអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់(កថាខណ្ឌទី១) និងអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់(កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ មុនអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់

មុននឹងឈានទៅកាន់ដំណាក់កាលនៃការដំណើរការនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ថាតើក្នុងនាមជាភាគីបណ្តឹងគួរត្រៀមលក្ខណៈទុកជាមុនដូចម្តេចខ្លះ ដើម្បីជាប្រយោជន៍ដល់ការជម្រះក្តីដែលនឹងប្រព្រឹត្តទៅក្នុងពេលខាងមុខ? យើងគួរសិក្សាស្វែងយល់ចំណុចមួយចំនួនដូចជា កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់(១) និងភស្តុតាងត្រៀមសម្រាប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់(២)។

#### ១. កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់

ជាដំបូង ក្នុងនាមជាភាគីត្រូវទទួលព័ត៌មានឱ្យបានច្បាស់លាស់ទាក់ទងនឹងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ព្រោះថាភាគីណាមួយមិនគួរអវត្តមានឡើយក្នុងកាលបរិច្ឆេទដ៏សំខាន់មួយនេះ ដែលអាចបណ្តាលឱ្យប៉ះពាល់ដល់ដំណើរការនៃរឿងក្តីបាន។ កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបានរៀបចំឡើងដោយតុលាការ ដោយកាលបរិច្ឆេទនោះ តុលាការគួរត្រូវរកពេលវេលាណាមួយឱ្យបាន

---

[28] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១១៥ (ការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី២។

[29] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី១។

សមរម្យមួយសម្រាប់ភាគីទាំងសងខាងអាចមានវត្តមានចូលរួមបាន[30] ដើម្បីជានាឱ្យបានការអនុវត្តការកាត់ក្តីដោយផ្អែកលើគោលការណ៍ចំពោះមុខ សម្រាប់ភាគីទាំងសងខាងធ្វើការអះអាងពីការការពារផលប្រយោជន៍របស់ពួកគេ។

**២. ភស្តុតាងត្រៀម**

សម្រាប់ភស្តុតាងត្រៀមនេះ ក្នុងនាមជាភាគី យើងក៏ត្រូវត្រៀមឱ្យស្រេចពីភស្តុតាង ដែលនឹងត្រូវដាក់ជូនតុលាការត្រួតពិនិត្យ ដើម្បីឱ្យការជម្រះក្តីរបស់ភាគី មានប្រៀបជាងភាគីម្ខាងទៀត ប៉ុន្តែត្រង់ចំណុចនៃការត្រៀមដាក់ភស្តុតាងនេះ ភាគីត្រូវប្រាកដឱ្យបានច្បាស់លាស់ថា ភស្តុតាងដែលត្រៀមនឹងដាក់ឱ្យតុលាការពិនិត្យ ត្រូវតែមានសារៈសំខាន់ និងជាភស្តុតាងដែលមានតម្លៃ ដែលអាចប្រើការជាប្រយោជន៍សម្រាប់ភាគីនៅក្នុងរឿងក្តីបាន។ ដោយឡែកការត្រៀមភស្តុតាងលើកនេះ មានលក្ខណៈខុសពីឯកសារត្រៀមនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលមានការអនុញ្ញាតត្រឹមតែភស្តុតាងជាឯកសារប៉ុណ្ណោះ ដោយការអនុញ្ញាតឱ្យដាក់ភស្តុតាងនៅក្នុងដំណាក់កាលនៃការដំណើរការនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់វិញ មានដូចជាសាក្សី កោសលវិច័យ និងរួមទាំងភស្តុតាងជាឯកសារជាដើម។

**កថាខណ្ឌទី២៖ អំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់**

អំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់ គឺជាពេលវេលាមួយដែលតុលាការ បានធ្វើការបើកសវនាការ ដើម្បីជំនុំជម្រះរឿងក្តីដែលកំពុងមានវិវាទ និងដើម្បីចេញសាលក្រមអំពីភាពត្រឹមត្រូវនៃបណ្តឹងនោះ ដោយអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់នោះ ត្រូវបានកំណត់ និងធ្វើការបែងចែកជាសកម្មភាពសំខាន់ៗ ចំនួន៣ ដែលមានដូចជាសេចក្តីថ្លែងការណ៍របស់ភាគី(១) ការពិនិត្យភស្តុតាង(២) និងការវិនិច្ឆ័យរបស់ចៅក្រម(៣)។

**១. សេចក្តីថ្លែងការណ៍របស់ភាគី**

ភាគីនីមួយៗ ត្រូវធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន ពីលទ្ធផលដែលទទួលបាននៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយសេចក្តីថ្លែងការណ៍នេះដែរ ភាគីអាចនិយាយរួមបញ្ចូលជាមួយអង្គហេតុ និងភស្តុតាងថ្មីបានបើមាន[31] ដើម្បីជាជំនួយសម្រាប់រឿងក្តីដែលកំពុងដំណើរការនោះ និងអាចប្រព្រឹត្តទៅបានដូចខាងក្រោមនេះ៖

---

[30] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១១៥ (ការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី១។

[31] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១១៦ (សេចក្តីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផល) កថាខណ្ឌទី៣។

- សេចក្តីថ្លែងការណ៍ដោយសង្ខេបលើអង្គហេតុៈ ភាគីទាំងសងខាងត្រូវធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងដោយសង្ខេបលើអង្គហេតុ ដែលនាំឱ្យមានវិវាទកើតឡើង ជូនទៅកាន់អង្គតុលាការទាំងមូល ដោយភាគីខាងដើមចោទ ត្រូវធ្វើសេចក្តីថ្លែងការណ៍ពីមូលហេតុ និងកម្មវត្ថុនៃការទាមទារ រីឯភាគីខាងចុងចម្លើយត្រូវធ្វើសេចក្តីថ្លែងការណ៍ពីមូលហេតុ និងការច្រានចោលការទាមទាររបស់ភាគីម្ខាងទៀត
- សេចក្តីថ្លែងការណ៍លើភស្តុតាងបន្ថែមៈ ភាគីក៏ត្រូវថ្លែងការណ៍ពីការដាក់ស្នើសុំតុលាការនូវភស្តុតាងបន្ថែម ដែលជាជំនួយក្នុងរឿងក្តីផងដែរ។

**២. ការពិនិត្យភស្តុតាង**

ការពិនិត្យភស្តុតាង គឺជាពេលវេលាដែលតុលាការត្រូវពិនិត្យភស្តុតាងតាមរយៈការស្នើសុំរបស់ភាគីនៅក្នុងបណ្តឹង[32] ដោយភាគីត្រូវបំភ្លឺឱ្យបានច្បាស់លាស់ និងក្បោះក្បាយទៅលើភស្តុតាងដែលខ្លួនបានដាក់ស្នើសុំមកតុលាការ ដោយធ្វើការផ្ទៀងផ្ទាត់ភស្តុតាងជាមួយនឹងអង្គហេតុឱ្យមានភាពត្រូវគ្នា[33] និងមានសារៈប្រយោជន៍ក្នុងរឿងក្តីដែរ។ ដោយការត្រួតពិនិត្យភស្តុតាងនេះ ត្រូវធ្វើឡើងនៅក្នុងអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង និងតម្រូវឱ្យតុលាការ ត្រូវតែធ្វើឡើងដោយសមូហវិធី[34] ដែលមានដូចជាៈ

- ការសាកសួរសាក្សីៈ ការសាកសួរសាក្សី ក៏ចាត់ទុកថាជាការពិនិត្យភស្តុតាងដែរ ព្រោះសាក្សីគឺជាភស្តុតាងរស់ ដែលអាចផ្តល់ចម្លើយនៅក្នុងអង្គហេតុបាន និងមានសារៈសំខាន់សម្រាប់ដំណើរការកាត់ក្តីក្នុងការស្វែងរកការពិត ដោយមុននឹងផ្តល់ចម្លើយសាក្សីត្រូវធ្វើសម្បថជាមុនសិន ព្រោះនេះជាវិធីតែមួយគត់ដែលអាចធានាបានថា សាក្សីប្រាកដជាបានផ្តល់ចម្លើយពិត និងមិនក្លែងបន្លំអង្គហេតុ។
- ការសាកសួរសាមីភាគីៈ សាមីភាគីពេលខ្លះក៏មិនបានផ្តល់អង្គហេតុគ្រប់ជ្រុងជ្រោយនោះដែរ ដោយស្ថិតក្រោមហេតុផលមួយចំនួនដូចជាៈ
    - ✓ ដោយសាមីភាគីបានគិតថា អង្គហេតុនោះមិនមានសារៈសំខាន់ ទើបសម្រេចមិននិយាយឬសរសេរនៅក្នុងពាក្យបណ្តឹង។
    - ✓ ភាគីបានទទួលការគម្រាមគំហែងពីជនដទៃ ដោយមិនឱ្យបញ្ចេញអង្គហេតុមួយចំនួន។

---

[32] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១២៤ (ការពិនិត្យភស្តុតាង) កថាខណ្ឌទី១។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១២៥ (ការស្នើសុំឱ្យពិនិត្យភស្តុតាង) កថាខណ្ឌទី២។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១២៧ (ការពិនិត្យភស្តុតាងដោយសមូហវិធី) កថាខណ្ឌទី១ និងកថាខណ្ឌទី២។

- ✓ ភាគីបារម្ភពីសុវត្ថិភាពអ្នកពាក់ព័ន្ធ ទើបលាក់បាំងមិនហ៊ាននឹងនិយាយ។
- ✓ សាមីភាគីបានយល់ឃើញថា ការផ្ដល់ ឬសរសេរអង្គហេតុនោះនៅក្នុងពាក្យបណ្ដឹង អាចនឹងធ្វើឱ្យភាគីម្ខាងទៀតមានប្រៀបជាង ទើបសម្រេចមិនបញ្ចេញអង្គហេតុ ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួន។
- ✓ ដោយសារការភ្លេចភ្លាំងជាបណ្ដោះអាសន្នរបស់សាមីភាគីជាដើម។

ក្រោមហេតុផលទាំងនោះហើយទើបតុលាការ និងច្បាប់បានសន្មតថា ការសាកសួរសាមីភាគីក៏ជាការពិនិត្យភស្តុតាងដែរ ដោយពេលខ្លះសាមីភាគីបានបញ្ចេញអង្គហេតុពិត ដោយចេតនា ឬអចេតនាចេញពីការសារសួរដោយសមូហវិធី ដែលនេះបង្ហាញឱ្យឃើញថា ការសាកសួរសាមីភាគីពិតជាមានសារៈសំខាន់ និងមិនអាចរំលងបានទេ។

- កោស័លវិច័យដោយតុលាការៈ តុលាការនឹងធ្វើកោសលវិច័យដោយផ្អែកលើការស្នើសុំរបស់ភាគី និងត្រូវសួរយោបល់ទៅកាន់ភាគីម្ខាងទៀតពីការធ្វើកោសលវិច័យនោះ[35] ដើម្បីធ្វើការស្វែងរកភស្តុតាងបន្ថែមសម្រាប់ដាក់ឱ្យត្រួតពិនិត្យក្នុងសវនាការ។
- ភស្តុតាងជាឯកសារៈ ភស្តុតាងជាឯកសារ ត្រូវបានស្នើសុំត្រួតពិនិត្យដោយតុលាការ ឯកសារដែលសាមីភាគីមាន ឬឯកសារពីភាគីផ្សេងទៀត ដែលមិនមែនជាភាគីក្នុងបណ្ដឹង ដែលតុលាការត្រូវធ្វើការស្នើសុំឱ្យភាគីដែលជាម្ចាស់ឯកសារ ផ្ដល់ឯកសារនោះមកកាន់តុលាការបាន។[36]

**៣. ការវិនិច្ឆ័យរបស់ចៅក្រម**

បន្ទាប់ពីបានបញ្ចប់សេចក្ដីថ្លែងការណ៍របស់ភាគី និងការពិនិត្យភស្តុតាងរួចរាល់ហើយ តុលាការនឹងបើកការអនុញ្ញាតម្ដងទៀត ដើម្បីឱ្យភាគីនីមួយៗ ធ្វើការទាញហេតុផលជាចុងក្រោយបាន នៅមុនពេលដែលតុលាការបិទបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់នេះ[37] ក្នុងគោលបំណងចង់ឱ្យភាគីទាំងសងខាងធ្វើសេចក្ដីសន្និដ្ឋានជាចុងក្រោយមួយ បន្ទាប់ពីបានឃើញ និងស្ដាប់លទ្ធផលនៃដំណាក់កាលនៃការត្រួតពិនិត្យភស្តុតាងរួចមក ព្រោះថាបន្ទាប់ពីបានឆ្លងកាត់ដំណាក់កាលនេះហើយ ភាគីនីមួយៗ អាចនឹងមានគំនិត និងការ

---

[35] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១៤៣ (ការស្នើសុំឱ្យធ្វើកោសលវិច័យ) កថាខណ្ឌទី១ និង កថាខណ្ឌទី៣។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១៤៨ (ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ) កថាខណ្ឌទី១ និងកថាខណ្ឌទី២។

[37] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១១៦ (សេចក្ដីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផល) កថាខណ្ឌទី៥។

ពិចារណាថ្មី ដោយផ្អែកលើលទ្ធផលនៃរកការឃើញនៅក្នុងចំណុចវិវាទ។

បន្ទាប់ពីការទាញហេតុផលដោយផ្ទាល់មាត់បានចប់រួចរាល់ជាស្ថាពរ នោះតុលាការនឹងអាចបញ្ចេញសកម្មភាពវិនិច្ឆ័យ១ ក្នុងចំណោម២ ដែលមានដូចជា៖

- ការប្រកាសដោយផ្ទាល់មាត់ពីសាលក្រមចុងក្រោយ ដោយផ្អែកលើលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងលទ្ធផលពិនិត្យភស្តុតាងកន្លងមក។[38]
- ដោយផ្អែកលើលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងលទ្ធផលពិនិត្យភស្តុតាងកន្លងមក មិនទាន់អាចឱ្យតុលាការចេញសាលក្រមចុងក្រោយបាន នោះតុលាការនឹងសម្រេចឱ្យធ្វើការទាញហេតុផលដោយផ្ទាល់មាត់សារឡើងវិញ៕[39]

[38] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១៨០ (សាលក្រមចុងក្រោយ) កថាខណ្ឌទី១។

[39] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១១៦ (សេចក្តីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផល) កថាខណ្ឌទី៤។

# ជំពូកទី៣

# ការបញ្ឈប់បណ្តឹង

# ជំពូកទី៣៖ ការបញ្ចប់បណ្តឹង

បន្ទាប់ពីបានឆ្លងកាត់ដំណាក់កាលនៃដំណើរការដាក់ពាក្យបណ្តឹង និងការជម្រះក្តីនៅសវនាការសាលាដំបូងរួចមក ឥឡូវនេះយើងនឹងឈានមកកាន់ការបញ្ចប់បណ្តឹងវិញម្តង ដែលការបញ្ចប់បណ្តឹង គឺជាដំណាក់កាលចុងក្រោយបន្ទាប់ពីការបញ្ចប់ជំពូកទី១ បណ្តឹងរដ្ឋប្បវេណី(ការចាប់ផ្តើមបណ្តឹង) និងជំពូកទី២ ដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១(ដំណើរការកាត់ក្តីក្នុងសវនាការសាលាដំបូង)។ ហើយការបញ្ចប់បណ្តឹងជាទូទៅត្រូវបានគេដឹងថា មាន២របៀប គឺការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី និងការបញ្ចប់បណ្តឹងដោយសាលក្រមចុងក្រោយរបស់តុលាការ ដោយជំពូកនេះនឹងធ្វើការរៀបរាប់ពី ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី(ផ្នែកទី១) ការបញ្ចប់បណ្តឹងដោយសកម្មភាពតុលាការ(ផ្នែកទី២) និងនីតិវិធីនៃការអនុវត្តផ្សេងទៀត(ផ្នែកទី៣)។

## ផ្នែកទី១៖ ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី

ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី មានន័យថាជាការបញ្ចប់បណ្តឹងដោយភាគីនីមួយៗ ឬក៏ភាគីណាម្ខាងបានធ្វើសកម្មភាពមួយចំនួន ដែលនាំឱ្យបណ្តឹងនោះមានការរលត់ ឬត្រូវបានបញ្ចប់ ឬក្រោមហេតុផលផ្សេងទៀត ដែលច្បាប់បានធ្វើការសន្មតថាបណ្តឹងនោះបញ្ចប់បាន។ ដោយមកដល់ចំណុចនេះ យើងនឹងធ្វើការសិក្សាស្វែងយល់ពីការបញ្ចប់ដោយភាគី(កថាខណ្ឌទី១) និងការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ(កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ ការបញ្ចប់បណ្តឹងដោយភាគី

ការបញ្ចប់បណ្តឹងដោយភាគីមានន័យថា ជាការបញ្ចប់បណ្តឹងដោយភាគីនីមួយៗ ឬភាគីណាម្ខាងទទួលសារភាព ឬទទួលស្គាល់ការទាមទារ ឬលះបង់ការទាមទារ ដោយនៅក្នុងកថាខណ្ឌនេះ យើងនឹងស្វែងយល់ចំណុចនៃការបញ្ចប់បណ្តឹងដោយភាគី ដែលមានដូចជាការដកពាក្យបណ្តឹង(១) ការសះជាតាមផ្លូវបណ្តឹង(២) ការលះបង់ ឬការទទួលស្គាល់ការទាមទារ(៣)។

#### ១. ការដកពាក្យបណ្តឹង

ការដកពាក្យបណ្តឹង គឺជាសកម្មភាពដែលភាគីខាងដើមបណ្តឹងរដ្ឋប្បវេណី ដកពាក្យដោយមិនប្តឹងចុងចម្លើយវិញ ក្រោមហេតុផលដែលភាគីខ្លួនឯងផ្ទាល់យល់ឃើញថាត្រឹមត្រូវ និងសមរម្យ ព្រោះថានៅក្នុងច្បាប់រដ្ឋប្បវេណីយើងបានគោរពគោលការណ៍ស្វ័យភាពរបស់បុគ្គលនីមួយៗ ប៉ុន្តែការដកពាក្យបណ្តឹងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនេះដែរ ក៏ត្រូវគោរពតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ពោលគឺមិនអាចចេះតែដកតាមតែការយល់ឃើញរបស់ភាគីបាននោះទេ គឺត្រូវស្របតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ការដកពាក្យបណ្តឹងរបស់ដើមចោទដោយខ្លួនឯងផ្ទាល់ត្រូវមានអានុភាព នៅមុនពេលដែលភាគីខាងចុងចម្លើយបានផ្តល់ឯកសារត្រៀមអំពីអង្គសេចក្តី

- ការដកពាក្យបណ្ដឹងរបស់ដើមចោទ ត្រូវមានការយល់ព្រមពីចុងចម្លើយដែរ ក្នុងករណីការដំណើរការក្ដីស្ថិតក្នុងអំឡុងពេលដែលចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្ដី រហូតដល់ដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់លើអង្គសេចក្ដីរួចរាល់
- ការដកពាក្យបណ្ដឹងរបស់ដើមចោទ នឹងមានអានុភាពនៅពេលដែលចុងចម្លើយមិនបានប្ដឹងតវ៉ាលើការដកពាក្យបណ្ដឹងនោះ ក្នុងរយៈពេល២សប្ដាហ៍ គិតចាប់ពីថ្ងៃដែលតុលាការ បានបញ្ជូនលិខិតអំពីការដកពាក្យបណ្ដឹងនោះទៅចុងចម្លើយ។[40]
- ក៏ត្រូវបានចាត់ទុកថាដកពាក្យបណ្ដឹងដែរ ក្នុងករណីដើមចោទ និងចុងចម្លើយមិនមានវត្តមានទាំងសងខាងក្នុងសវនាការ នាដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬការទាញហេតុផលដោយផ្ទាល់មាត់ និងមិនបានធ្វើបណ្ដឹងសារជាថ្មីក្នុងរយៈពេលមួយខែ នៃកាលបរិច្ឆេទដែលកំណត់ដោយតុលាការ។[41]

ក្រោមលក្ខខណ្ឌទាំងអស់នេះហើយ នាំឱ្យការដកពាក្យបណ្ដឹងរបស់ភាគីដែលបានដាក់ពាក្យបណ្ដឹងនោះ មានអានុភាពស្របតាមច្បាប់កំណត់ និងជាលទ្ធផលមួយដែលនាំឱ្យបណ្ដឹងនោះត្រូវបានបញ្ចប់ដែរ ឬហៅម្យ៉ាងទៀតថា ការបញ្ចប់បណ្ដឹងដោយការដកពាក្យបណ្ដឹងរបស់ភាគី។

**២. ការសះជាតាមផ្លូវបណ្ដឹង**

ការសះជាតាមផ្លូវបណ្ដឹង មានន័យថា ជាភាពជោគជ័យលើការផ្សះផ្សារបស់ភាគី ក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬការទាញហេតុផលដោយផ្ទាល់មាត់ ឬនៅទីណា ពេលវេលាណាក៏បាន ឱ្យតែការផ្សះផ្សានោះមានភាពសមរម្យ និងត្រឹមត្រូវ[42] ដែលសកម្មភាពនៃការសះជាតាមផ្លូវបណ្ដឹងនេះ នាំឱ្យលទ្ធផលនៃបណ្ដឹងត្រូវបានបញ្ចប់ដូចគ្នាទៅនឹងការដកពាក្យបណ្ដឹងដែរ។ ការសះជាតាមផ្លូវបណ្ដឹង គឺជាលទ្ធផលដែលគ្រប់គ្នារំពឹងទុក និងចង់បាន ព្រោះថាច្បាប់ក៏ដូចជាតុលាការមិនចង់ឱ្យពលរដ្ឋមានវិវាទនឹងគ្នានោះទេ ពោលគឺត្រូវមានការអត់អោនឱ្យគ្នាទៅវិញទៅមក រស់នៅដោយសហការ និងសាមគ្គីគ្នាគ្រប់កាលៈទេសៈក្នុងនាមជាពលរដ្ឋនៃម្ចាស់ប្រទេសរួម ជៀសវាងការបង្កឱ្យមានវិវាទនឹងគ្នាកើតឡើង ដែលនាំឱ្យខាតបង់ទាំងថវិកា ខាតបង់ទាំងពេលវេលា។

[40] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា២១៧ (ការដកពាក្យបណ្ដឹង) កថាខណ្ឌទី៥។

[41] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា២១៩ (ការចាត់ទុកថា ដកពាក្យបណ្ដឹង)។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា២២០ (ការផ្សះផ្សាបណ្ដឹង)។

**៣. ការលះបង់ ឬការទទួលស្គាល់ការទាមទារ**

ការលះបង់ ឬការទទួលស្គាល់ការទាមទារ គឺជាការលះបង់ការទាមទាររបស់ដើមចោទទៅលើចុងចម្លើយដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ត្រង់ចំណុចកម្មវត្ថុនៃការទាមទារដែលបានធ្វើឡើងដោយភាគីខាងដើមចោទ ឬជាការទទួលស្គាល់របស់ចុងចម្លើយលើការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្ដឹង។ ការលះបង់ ឬការទទួលស្គាល់ការទាមទាររបស់ភាគីដើមចោទ ឬចុងចម្លើយ ភាគីណាម្ខាងត្រូវថ្លែងការណ៍ដោយផ្ទាល់មាត់ក្នុងពេលដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការត្រៀមហេតុផល ឬនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់។[43]

**កថាខណ្ឌទី២៖ ការបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិ**

ការបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិនៅត្រង់នេះ ក៏បានកើតចេញពីសកម្មភាពរបស់ភាគីដែរ មានន័យថាបណ្ដឹងនឹងត្រូវរលត់ ឬបញ្ចប់បើភាគីនោះ លែងមានវត្តមានសម្រាប់បន្តការដំណើរការក្ដី ដោយសារមរណភាពរបស់ភាគី(១) & ករណីដែលដើមចោទ និងចុងចម្លើយក្លាយជាបុគ្គលតែម្នាក់(២)។

**១. មរណភាពរបស់ភាគី**

បណ្ដឹងមួយមិនអាចដំណើរការជាបន្តទៀតបានទេ បើភាគីដែលនឹងត្រូវធ្វើការតទល់គ្នានៅក្នុងសវនាការ លែងមានវត្តមានដោយសារមូលហេតុទទួលមរណភាព ក្នុងអំឡុងពេលនៃការធ្វើបណ្ដឹង ឬកំពុងដំណើរការបណ្ដឹង ដែលជាហេតុនាំឱ្យបណ្ដឹងនោះរលត់ដោយស្វ័យប្រវត្តិ។ ជាការពិត មរណភាពរបស់ភាគី មិនមែនជាបញ្ហាចម្បង ដែលនាំឱ្យបណ្ដឹងរលត់ដោយស្វ័យប្រវត្តិទេ ដោយបញ្ហាចម្បងនោះ គឺមិនមានអ្នកបន្តជំនួសនៅក្នុងដំណើរការនៃនីតិវិធីបណ្ដឹង ឧទាហរណ៍ ករណីបណ្ដឹងលែងលះ បើភាគីម្ខាងនៅក្នុងបណ្ដឹងលែងលះ បានទទួលមរណភាព នោះមិនអាចមានភាគីផ្សេងទៀត ឬអ្នកតំណាងតាមផ្លូវបណ្ដឹងណាមួយ មកលែងលះជំនួសឱ្យភាគីដែលបានស្លាប់នោះបានទេ។

**២. ករណីដែលដើមចោទ និងចុងចម្លើយក្លាយជាបុគ្គលតែម្នាក់**

ដោយផ្អែកលើសេចក្ដីពន្យល់អំពីចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១នីតិវិធីចេញសាលក្រម កថាភាគទី២ កថាខណ្ឌទី៣ ទំព័រ១៥៨ បាននិយាយថា " *...ករណីដែលភាគីណាម្ខាងបានទទួលមរណភាព ឬបានរលត់ដោយសារការរួមបញ្ចូលនៃនីតិបុគ្គល ហើយសិទ្ធិ និងកាតព្វកិច្ចដែលកម្មវត្ថុនៃបណ្ដឹងនោះ ត្រូវធ្លាក់ទៅលើបុគ្គលតែម្នាក់។ នេះជាករណីដែលដើមចោទ និងចុងចម្លើយបានក្លាយជាបុគ្គលតែម្នាក់ ដោយសារតែភាគីម្ខាងបានទទួលបន្តឋានៈតាមផ្លូវបណ្ដឹងរបស់ភាគីម្ខាងទៀត ដោយសារសន្តិកម្ម ឬការរួមបញ្ចូលនៃនីតិបុគ្គល។*" នេះក៏ជាមូលហេតុសំខាន់

[43] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា២២១ (ការលះបង់ ឬការទទួលស្គាល់ការទាមទារ)។

មួយដែលនាំឱ្យបណ្តឹងបានរលត់ដោយស្វ័យប្រវត្តិដែរ ព្រោះថាបើកាលណាសិទ្ធិ និងកាតព្វកិច្ចដែលមានការទាមទារនៅក្នុងកម្មវត្ថុនៃពាក្យបណ្តឹងនោះ ត្រូវធ្លាក់លើបុគ្គលតែម្នាក់ ក្នុងករណីការជម្រះរឿងក្តីនៅតែបន្ត នាំឱ្យការជម្រះក្តីនោះក្លាយជាមិនបានការ ដោយសារតែដើមចោទ និងចុងចម្លើយបានរួមបញ្ចូលតែមួយទៅហើយ។

**ផ្នែកទី២៖ ការបញ្ចប់បណ្តឹងដោយសកម្មភាពតុលាការ**

ការបញ្ចប់បណ្តឹងដោយសកម្មភាពតុលាការ ជាទូទៅត្រូវបានគេដឹងថាមាន៣ដំណាក់កាលសំខាន់ៗដូចជា ទី១នីតិវិធីនៃការដាក់ពាក្យបណ្តឹង ទី២នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងទី៣នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយរួមបញ្ចូលវិធីសាស្ត្រដែលបានរៀបរាប់ខាងលើ តុលាការនឹងធ្វើការបញ្ចប់បណ្តឹង ដោយការប្រកាសសាលក្រមចុងក្រោយមួយ។ ដោយហេតុថា នៅក្នុងនីតិវិធីនៃការដាក់ពាក្យបណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ យើងបានសិក្សា និងឆ្លងកាត់ខាងលើរួចហើយ ដូច្នេះយើងនឹងធ្វើការស្វែងយល់ពីសកម្មភាពមួយចុងក្រោយរបស់តុលាការវិញម្តង គឺការប្រកាសសាលក្រម(កថាខណ្ឌទី១)។

**កថាខណ្ឌទី១៖ ការប្រកាសសាលក្រម**

ការប្រកាសសាលក្រមត្រូវធ្វើឡើងដោយការប្រកាសរបស់តុលាការ បន្ទាប់ពីបានឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់រួចមក ដោយសាលក្រមនោះនឹងមានអានុភាពបន្ទាប់ពីបានប្រកាស។[44] ដូច្នេះមានចំណុចពិសេសមួយចំនួន ដែលទាក់ទងនឹងការប្រកាសសាលក្រមដោយតុលាការ ដែលយើងគួរសិក្សាស្វែងយល់បន្ថែមដូចជាប្រភេទនៃសាលក្រម(១) និង ការប្រកាសសាលក្រមចុងក្រោយ(២)។

**១. ប្រភេទនៃសាលក្រម**

មុននឹងឈានចូលទៅកាន់ការប្រកាសសាលក្រមដោយតុលាការ យើងគួរសិក្សាស្វែងយល់ប្រភេទនៃសាលក្រមជាមុនសិន ដែលសាលក្រមនៅក្នុងរឿងក្តីរដ្ឋប្បវេណីនីមួយៗ សុទ្ធតែមានគោលបំណង និងខ្លឹមសារផ្សេងៗគ្នាទៅតាមករណីនៃបទល្មើសនីមួយៗ ដោយការសម្រេចចេញសាលក្រមប្រភេទណាមួយ គឺត្រូវបានចៅក្រមជាអ្នកសម្រេចដោយផ្អែកតាមការយល់ឃើញក្នុងរឿងក្តី ឬក៏អាចហៅម្យ៉ាងទៀតថា ការសម្រេចដោយផ្អែកតាមឆន្ទានុសិទ្ធិរបស់ចៅក្រម។ ដូច្នេះ ថាតើសាលក្រមមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ក្រមមិនបានធ្វើការរៀបរាប់ ឬផ្តល់ចម្លើយត្រង់ៗ សម្រាប់សំណួរមួយនេះទេ ប៉ុន្តែគេសង្កេតឃើញថានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមានកំណត់ពីសាលក្រមដែលតុលាការត្រូវប្រកាស មានលក្ខណៈផ្សេងៗគ្នាតាមមាត្រានីមួយៗស្តីពីសាលក្រមនោះ។ ដូច្នេះ គេក៏បានសន្មតថា សាលក្រមក្នុងរឿងក្តីរដ្ឋប្បវេណីមាន៣ប្រភេទគឺ៖

---

[44] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១៨៦ (កំណើតអានុភាពនៃសាលក្រម)។

- សាលក្រមចុងក្រោយ៖ គឺជាសាលក្រមដែលធ្វើឡើងដោយតុលាការ បន្ទាប់ពីបានឆ្លងកាត់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងកន្លងមក។[45] សាលក្រមនេះជាសាលក្រមដែលបិទបញ្ចប់រឿងក្តីនៅសាលាដំបូង ប៉ុន្តែបើភាគីនីមួយៗ មិនពេញចិត្តនឹងសាលក្រមចុងក្រោយរបស់តុលាការសាលាដំបូង ឬការជម្រះក្តីលើកទី១នេះទេ ពួកគេអាចធ្វើបណ្តឹងទៅតុលាការជាន់ខ្ពស់ពីការមិនសុខចិត្តលើសាលក្រមចុងក្រោយនេះជាបន្តបាន។[46]
- សាលក្រមរបៀប៖ សាលក្រមប្រភេទនេះវិញ មិនមានអានុភាពបញ្ចប់បណ្តឹងនោះទេ ពោលគឺវាជាសាលក្រមដែលតុលាការវិនិច្ឆ័យលើហេតុណាមួយនៅក្នុងវិវាទឱ្យចរាល់សិន មុននឹងធ្វើការដោះស្រាយចំណុចនៃការទាមទារក្នុងវិវាទនោះ ក្រោមលក្ខខណ្ឌដែលច្បាប់ចែងមួយចំនួនដូចជា៖
    - ✓ អត្ថិភាពនៃការទាមទារ ក្នុងករណីមានវិវាទអំពីអត្ថិភាព និងចំនួនទឹកប្រាក់នៃការទាមទារ៖ មានន័យថា តុលាការអាចចេញសាលក្រមរបៀបបាន លើការវិនិច្ឆ័យវិវាទអំពីអត្ថិភាពនៃសិទ្ធិជាមុនសិន
    - ✓ មធ្យោបាយតទល់ ឬការពារខ្លួន ដែលអាចវិនិច្ឆ័យដាច់ដោយឡែកបាន៖ មធ្យោបាយដែលអាចវិនិច្ឆ័យដាច់ដោយឡែកបាន មានន័យថា មធ្យោបាយនោះមានអានុភាពគតិយុត្ត ដែលអាចធ្វើការអះអាងបាននៅក្នុងរឿងក្តី
    - ✓ អត្ថិភាព ឬនត្ថិភាពនៃលក្ខខណ្ឌបណ្តឹង៖ ចំណុចនេះតុលាការគួរចេញសាលក្រមរបៀប បើលក្ខខណ្ឌនៃបណ្តឹងមានភាពមិនត្រឹមត្រូវ ដូចជាដែនសមត្ថកិច្ចនៃសាលាជម្រះក្តី ឬអសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគីជាដើម ដែលជាមូលហេតុនាំអោយការជម្រះក្តីនៅតុលាការនោះ មិនមានអានុភាពតាមផ្លូវច្បាប់
    - ✓ ហេតុដែលទាក់ទងនឹងការបញ្ចប់បណ្តឹង៖ លក្ខខណ្ឌចុងក្រោយនេះ គឺជាសាលក្រមរបៀបដែលតុលាការចេញ ដើម្បីបញ្ចប់បណ្តឹង ឬក៏អាចហៅម្យ៉ាងទៀតថា សាលក្រមរបៀបនៃការបញ្ចប់បណ្តឹង ដោយតុលាការសម្រេចចេញសាលក្រមនេះក្នុងករណីដែលភាគីបានដកពាក្យបណ្តឹង មានការសះជាតាមផ្លូវបណ្តឹង ឬមរណភាពរបស់ភាគីជាដើម។[47]

---

[45] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១៨០ (សាលក្រមចុងក្រោយ) កថាខណ្ឌទី១។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍) កថាខណ្ឌទី១។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១៨១ (សាលក្រមរបៀប)។

- សាលក្រមកំបាំងមុខ៖ ជាសាលក្រមដែលនឹងប្រកាសដោយតុលាការ ទោះបីជាភាគីណាម្ខាងមិនមានវត្តមានក្នុងអំឡុងពេលនៃកាលបរិច្ឆេទដែលបានកំណត់ក៏ដោយ។

**២. ការប្រកាសសាលក្រមចុងក្រោយ**

មូលហេតុដែលមានការលើកយកការប្រកាសសាលក្រមចុងក្រោយមកបកស្រាយក្នុងចំណុចនេះ គឺដើម្បីឱ្យមានភាពស៊ីគ្នានឹងអត្ថបទខាងលើ និងសមហេតុផលនឹងចំណងជើងជំពូកទី៣នេះដែរ។ ការប្រកាសសាលចុងក្រោយត្រូវធ្វើការប្រកាសដោយតុលាការផ្ទាល់ បន្ទាប់ពីបានស្តាប់ការបកស្រាយ និងការអះអាងពីការទាញហេតុផលដោយផ្ទាល់មាត់របស់ភាគីរួចមក ក៏ដូចជាបានត្រួតពិនិត្យភស្តុតាងដោយសាកសួរសាក្សី សាមីភាគី ការពិនិត្យភស្តុតាងជាឯកសារ និងកោសលវិច័យជាដើម។[48]

សាលក្រមចុងក្រោយនេះ អាចមានអត្ថន័យ២ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅពេលប្រកាស គឺទី១សាលក្រមចុងក្រោយ ដែលមានអត្ថន័យទទួលស្គាល់ការទាមទាររបស់ដើមចោទ និងទី២សាលក្រមចុងក្រោយដែលមានអត្ថន័យច្រានចោលការទាមទាររបស់ដើមចោទ ដែលតុលាការសម្រេចសេចក្តីនេះឡើងផ្អែកតាមអំណះអំណាង និងភស្តុតាងដែលភាគីនីមួយៗបានថ្លែងការណ៍កន្លងមក និងក៏ជាការវិនិច្ឆ័យ ការយល់ឃើញដែលកើតចេញពីឆន្ទានុសិទ្ធិរបស់តុលាការដែរ។

សាលក្រមចុងក្រោយនឹងមានអានុភាពចូលជាសាលក្រមស្ថាពរក្នុងអំឡុងពេលមួយខែ បើភាគីមិនបានធ្វើបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់ទេនោះ[49] ហើយសាលក្រមដែលចូលជាស្ថាពរនេះនឹងមានវិសាលភាពអនុវត្តលើ៖

- ភាគីបណ្តឹង
- បុគ្គលដែលឱ្យគេធ្វើបណ្តឹងជំនួស
- បុគ្គលដែលកាន់កាប់បន្តកម្មវត្ថុនៃការទាមទារក្នុងបណ្តឹង
- បុគ្គលដែលបានកាន់កាប់កម្មវត្ថុនៃការទាមទារក្នុងបណ្តឹង ដើម្បីប្រមូលផលប្រយោជន៍ជូនបុគ្គលដែលបានរៀបរាប់ខាងលើ។[50]

[48] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១៨០ (សាលក្រមចុងក្រោយ) កថាខណ្ឌទី១។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា២៦៤ (អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍) កថាខណ្ឌទី១។

[50] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ)។

## ផ្នែកទី៣៖ នីតិវិធីនៃការអនុវត្តផ្សេងទៀត

ក្រៅពីនីតិវិធីនៃការប្រកាសសាលក្រមចុងក្រោយ ឬការអនុវត្តសាលក្រមស្ថាពរ ក្រមនីតិវិធីរដ្ឋប្បវេណីក៏មានចែងនីតិវិធីផ្សេងទៀត ដើម្បីធ្វើការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាពលើវិវាទរដ្ឋប្បវេណីដែរ ព្រោះថាទោះបីជាសាលក្រមត្រូវបានតុលាការសម្រេចឱ្យអនុវត្តហើយក្តី ក៏នៅមានឧបសគ្គមួយចំនួនដែលបង្កឱ្យមានការរាំងស្ទះដល់ការអនុវត្តដែរ។ ដូច្នេះហើយទើបច្បាប់រដ្ឋប្បវេណីបានបង្កើតឱ្យមានវិធានការការពារមួយចំនួនដើម្បីអនុវត្តកុំឱ្យមានការកកស្ទះដល់ការអនុវត្តច្បាប់ ដោយការអនុវត្តនោះមាននីតិវិធីផ្សេងៗមួយចំនួន ដូចជានីតិវិធីដាស់តឿន(កថាខណ្ឌទី១) ការអនុវត្តដោយបង្ខំ(កថាខណ្ឌទី២) និងការចាត់ចែងរក្សាការពារ(កថាខណ្ឌទី៣)។

### កថាខណ្ឌទី១៖ នីតិវិធីដាស់តឿន

នីតិវិធីដាស់តឿន គឺជានីតិវិធីមួយដែលតុលាការចេញដីកាសម្រេចលើការដាស់តឿនកូនបំណុល អំពីកាតព្វកិច្ចសងជាប្រាក់តាមការទាមទាររបស់ម្ចាស់បំណុល ដែលការអនុវត្តនីតិវិធីដាស់តឿនមានគោលបំណងចង់ឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិរបស់ខ្លួនបានកាន់តែឆាប់រហ័ស ក្នុងករណីដែលកូនបំណុលបដិសេធមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នីតិវិធីដាស់តឿននេះ មានគោលដៅដាស់តឿនបុគ្គលដែលមិនព្រមធ្វើការអនុវត្តកាតព្វកិច្ចរបស់ខ្លួន បើបុគ្គលរូបនោះមិនព្រមអនុវត្តបន្ទាប់ពីទទួលបានសាលក្រមសម្រេចដាស់តឿននេះទៀត នោះតុលាការនឹងចាត់វិធានការបន្ទាប់។ ដើម្បីឱ្យបានកាន់តែជ្រាបច្បាស់ជាងនេះ យើងនឹងសិក្សាស្វែងយល់បន្ថែមសញ្ញាណទូទៅ(១) និងអានុភាពនៃដីកាសម្រេចដាស់តឿន(២)។

#### ១. លក្ខខណ្ឌចំពោះនីតិវិធីនៃការដាស់តឿន

ដើម្បីចេញសាលដីកា ឬសាលក្រមសម្រេចឱ្យដាស់តឿនបាន តុលាការត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- កម្មវត្ថុសម្រេចឱ្យដាស់តឿន៖ កម្មវត្ថុដែលសម្រេចស្នើសុំ ឱ្យតុលាការចេញដីកាសេចក្តីសម្រេចលើការដាស់តឿននោះ ត្រូវតែជាការទាមទារឱ្យសងប្រាក់[51] ឬការទាមទារឱ្យផ្តល់តាវកាលិក[52]។
- កូនបំណុលមិនអនុវត្តកាតព្វកិច្ច៖ កូនបំណុលបិសេធដោយស្ម័គ្រចិត្ត លើការមិនអនុវត្តកាតព្វកិច្ចដែលមានក្នុងកិច្ចសន្យា ដោយមិនសងប្រាក់ទៅម្ចាស់បំណុលជាដើម។
- ចំណុចដែលត្រូវសរសេរក្នុងដីកាដាស់តឿន៖ ដែលមានដូចខាងក្រោមនេះ៖

[51] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣១៩ (លក្ខខណ្ឌនៃដីកាសម្រេចដាស់តឿន)។

[52] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកការរៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី *សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម* ទំព័រ២៤២។

- ✓ ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ឬអ្នកតំណាង
- ✓ ដីកាដែលសម្រេចឱ្យតុលាការចេញតាមការទាមទាររបស់ម្ចាស់បំណុល
- ✓ អង្គហេតុចាំបាច់មួយចំនួន ដើម្បីបញ្ជាក់ការទាមទារ
- ✓ ចំនួនទឹកប្រាក់ដែលត្រូវសង
- ✓ បញ្ជាក់អំឡុងពេលនៃការធ្វើបណ្តឹងតវ៉ាលើដីកាដាស់តឿន បើភាគីពុំប្តឹងតវ៉ាក្នុងអំឡុងពេលកំណត់ នោះតុលាការនឹងអនុវត្តជាបណ្តោះអាសន្នតាមឆន្ទានុសិទ្ធិ។[53]

- បញ្ជូនដីកាសម្រេចនោះឱ្យដល់កូនបំណុល។[54]

**២. អានុភាពនៃដីកាសម្រេចដាស់តឿន**

ដីកាសម្រេចដាស់តឿន នឹងមានអានុភាពភ្លាម បន្ទាប់ពីបានបញ្ជូនទៅដល់កូនបំណុល[55] បើកូនបំណុលមិនព្រមធ្វើវិវាទលើដីកាសម្រេចដាស់តឿន នៅមុនអំឡុងពេល ២សប្តាហ៍នៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នទេនោះ ដីកាសម្រេចឱ្យដាស់តឿននឹងចូលជាស្ថាពរអំពីការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលការចូលជាស្ថាពរនេះនឹងមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពររបស់តុលាការដែរ[56] ហើយតុលាការនឹងអនុវត្តជាបណ្តោះអាសន្នតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

**កថាខណ្ឌទី២៖ ការអនុវត្តដោយបង្ខំ**

ការអនុវត្តដោយបង្ខំ គឺជានីតិវិធីដែលតុលាការ ក៏ដូចជាច្បាប់បានអនុញ្ញាតឱ្យភាគីដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគអាចធ្វើការទាមទារពីភាគីម្ខាងទៀត ដោយអនុវត្តការទាមទារដោយបង្ខំបាន[57] ដើម្បីសម្រេចទទួលបានសិទ្ធិ ឬការទាមទារដែលធ្វើឡើងដោយការស្នើសុំមកកាន់តុលាការរបស់ភាគីដែលមានសិទ្ធិក្នុងករណីដែលភាគីម្ខាងទៀតនោះមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ដូច្នេះដើម្បីស្វែងយល់ និងសិក្សាបន្ថែមការអនុវត្តដោយបង្ខំ យើងនឹងសិក្សាចំណុចមួយចំនួន ដូចជាលក្ខខណ្ឌចំពោះការអនុវត្តដោយបង្ខំ(១) និងកិច្ចការនៅពេលដែលអនុវត្តដោយបង្ខំ(២)។

---

[53] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា ៣២៤ (ចំណុចដែលត្រូវសរសេរបញ្ជាក់ក្នុងដីកាសម្រេចដាស់តឿន)។

[54] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣២៥ (ការបញ្ជូនដីកាសម្រេចដាស់តឿន) កថាខណ្ឌទី១។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣២៥ (ការបញ្ជូនដីកាសម្រេចដាស់តឿន) កថាខណ្ឌទី២។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៣៣ (អានុភាពនៃដីកាសម្រេចដាស់តឿន)។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៣៤ (គោលគំនិត)។

**១. លក្ខខណ្ឌចំពោះការអនុវត្តដោយបង្ខំ**

លក្ខខណ្ឌចំពោះការអនុវត្តដោយបង្ខំ ឬការទាមទារឱ្យអនុវត្តដោយបង្ខំ គឺមានចែងក្នុងច្បាប់ និងធ្វើយ៉ាងណាឱ្យស្របតាមច្បាប់ ពោលគឺបង្ការកុំឱ្យមានការប៉ះពាល់ដល់សិទ្ធិបុគ្គលក្នុងពេលដែលអនុវត្តដោយបង្ខំ ព្រោះថាបើកាលណាការអនុវត្តច្បាប់មិនបានត្រឹមត្រូវទេនោះ នឹងនាំឱ្យមានការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គម និងសិទ្ធិមនុស្ស។ ហើយសញ្ញាណទូទៅ និងលក្ខខណ្ឌមួយចំនួនដែលត្រូវដឹងពីការអនុវត្តដោយបង្ខំនេះមានដូចខាងក្រោម៖

- ការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងដោយតុលាការអនុវត្ត ឬអាជ្ញាសាលា ដោយផ្អែកតាមការស្នើសុំរបស់ភាគីដែលទាមទារនោះ[58]
- ការអនុវត្តដោយបង្ខំ គឺត្រូវអនុវត្តដោយមានលក្ខណៈស្របតាមលិខិតអនុវត្ត(សូមចូលមើលក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣៥០ កថាខណ្ឌទី២ ដើម្បីស្វែងយល់ពីលិខិតអនុវត្ត)
- ការអនុវត្តដោយបង្ខំ មានវិសាលភាពលើភាគី ដែលមានចុះឈ្មោះ ឬនាមករណ៍នៅក្នុងលិខិតអនុវត្ត ឬបុគ្គលដែលទទួលបន្តសិទ្ធិ ឬកាន់កាប់កម្មវត្ថុនៃការទាមដែលបានកំណត់តាមច្បាប់[59]។

**២. កិច្ចការនៅពេលដែលអនុវត្តដោយបង្ខំ**

កិច្ចការនៅពេលដែលអនុវត្តដោយបង្ខំត្រូវគោរពតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងច្បាប់ដែរ ជាពិសេសក្រមនីតិវិធីរដ្ឋប្បវេណី ព្រោះក្រមនេះមានចែងពីកាតព្វកិច្ចរបស់អ្នកមានសមត្ថកិច្ច និងរបៀបរបបនៃការអនុវត្តនីតិវិធីមួយនេះ ដែលមានដូចតទៅ៖

- បើក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានរារាំង អាជ្ញាសាលាអាចប្រើប្រាស់កម្លាំងសមត្ថកិច្ចបាន ដូចជាកម្លាំងនគរបាលជាដើម។[60]
- បើពេលទៅដល់កន្លែងចុះសង្កេតការ តែបែរជាមិនជួបម្ចាស់កន្លែង ឬគ្មាននរណាម្នាក់នៅចាំកន្លែងនោះទេ អាជ្ញាសាលាចាំបាច់ត្រូវរកមេភូមិ ឬមេឃុំ ឬមន្ត្រីដែលប្រចាំការនៅទីនោះ មកធ្វើជាសាក្សីក្នុងការអនុវត្តនីតិវិធីនេះ។[61]

[58] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៣៦ (ស្ថាប័នអនុវត្ត) កថាខណ្ឌទី១ និង កថាខណ្ឌទី២។

[59] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ)។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍)។

[61] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៣៩ (អ្នកសង្កេតការណ៍)។

- បើកាលបរិច្ឆេទនៃការចុះអនុវត្តត្រូវនឹងថ្ងៃសម្រាក អាជ្ញាសាលាត្រូវសុំការអនុញ្ញាតពីតុលាការដែលបង្គាប់ឱ្យអនុវត្តនោះ ឬសាលាដំបូងដែលខ្លួនស្ថិតនៅ និងត្រូវបង្ហាញលិខិតអនុញ្ញាតនោះដែរ។[62]

**កថាខណ្ឌទី៣៖ ការចាត់ចែងរក្សាការពារ**

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដែលតុលាការសម្រេចរក្សាការពារកម្មវត្ថុនៃវិវាទ ដែលមានការស្នើសុំពីភាគី ដើម្បីឱ្យមានការចាត់ចែងរក្សាការពារនេះឡើង ក្នុងគោលដៅការពារកម្មវត្ថុនោះកុំឱ្យមានការប្រែប្រួលបច្ចុប្បន្នភាពរបស់វា ដែលជាហេតុនាំឱ្យមានការប៉ះពាល់ដល់ដំណើរការរឿងក្តីដែរ។ ដោយត្រង់ចំណុចនេះ យើងនឹងសិក្សាស្វែងយល់ពីអត្ថន័យ និងគោលបំណងនៃការចាត់ចែងរក្សាការពារនេះ(១) & ប្រភេទនៃការចាត់ចែងរក្សាការពារ(២)។

**១. អត្ថន័យ និងគោលបំណង**

អត្ថន័យនៃការចាត់ចែងរក្សាការពារសំដៅលើ ការចាត់ចែងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការទាមទារ ឱ្យរក្សាទម្រង់បច្ចុប្បន្នភាពរបស់វា តាមការស្នើសុំរបស់ភាគី ក្នុងករណីកុំឱ្យភាគីម្ខាងទៀតមានសិទ្ធិ ឬសកម្មភាពដែលនាំឱ្យខូចទ្រង់ទ្រាយដើមរបស់វា ឬក៏ធ្វើឱ្យមានគ្រោះថ្នាក់បន្ទាន់ដល់ភាគីដែលបានស្នើសុំបើកម្មវត្ថុនោះមិនត្រូវបានចាត់ចែងរក្សាការពារទេ ហើយសិទ្ធិនៃការចាត់ចែងរក្សាការពារនេះ ត្រូវធ្វើឡើងដោយពឹងផ្អែកលើអំណាចរដ្ឋ ដើម្បីការពារសិទ្ធិបុគ្គលណាម្នាក់។

ការចាត់ចែងរក្សាការពារ មានគោលបំណងការពារទុកជាមុន ក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបរាជ័យ ដោយមុលហេតុមានចំណុចខ្វះខាតក្នុងលក្ខខណ្ឌណាមួយ ដែលជាឧបសគ្គមិនអាចឱ្យការអនុវត្តដោយបង្ខំប្រព្រឹត្តទៅបាន ក្នុងករណីនេះហើយដែលនាំឱ្យមាននីតិវិធីនៃការចាត់ចែងរក្សាការពារនេះឡើង ជៀសវាងនាំឱ្យភាគីម្ខាងដឹងខ្លួនជាមុន ដោយសារកាអនុវត្តដោយបង្ខំ ហើយបញ្ចេញសកម្មភាពធ្វើឱ្យខូចស្ថានភាព ឬប្រយោជន៍ដែលភាគីម្ខាងទៀតបានទាមទារកម្មវត្ថុនោះ។

**២. ប្រភេទនៃការចាត់ចែងរក្សាការពារ**

ការចាត់ចែងរក្សារការពារ ក៏ត្រូវបានគេធ្វើការបែងចែកតាមប្រភេទដែរ ព្រោះថាប្រភេទនៃការចាត់ចែងរក្សារការពារនីមួយៗ មានគោលដៅអនុវត្តផ្សេងគ្នាតាមកម្មវត្ថុនៃការទាមទារនៃករណីនីមួយៗ ដែលភាគីបានស្នើសុំមកកាន់តុលាការ ដើម្បីឱ្យមានការចាត់ចែងរក្សាការពារនេះឡើង ក្នុងគោលបំណងការពារផលប្រយោជន៍ និងស្វែករកយុត្តិធម៌ជូនបុគ្គលដែលមានសិទ្ធិត្រឹមត្រូវស្របច្បាប់។ ការចាត់ចែងរក្សារការពារ ត្រូវបានច្បាប់ធ្វើការបែងចែកជា២ប្រភេទ មានដូចខាងក្រោម៖

---

[62] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៣៤០ (ការអនុវត្តនៅថ្ងៃឈប់សម្រាក ឬពេលយប់)។

- ការរឹបអូសជាបណ្តោះអាសន្ន៖ គឺជាការចាត់ចែងរក្សាការពារលើសិទ្ធិ ដែលសិទ្ធិនោះគឺជាសិទ្ធិចាត់ចែងលើប្រាក់ ដែលនឹងត្រូវសងទៅម្ចាស់បំណុលដោយកូនបំណុល។[63] មានន័យថា ជាការរឹបអូសសិទ្ធិរបស់បុគ្គលដែលមិនព្រមអនុវត្តកាតព្វកិច្ចក្នុងនាមជាកូនបំណុល ដោយសងជាប្រាក់ទៅម្ចាស់បំណុល ហើយត្រូវបានតុលាការចេញសាលក្រមបញ្ឈប់សិទ្ធិបណ្តោះអាសន្ន លើការចាត់ចែងប្រាក់ដែលកូនបំណុលនោះមាន។
- ការចាត់ចែងជាបណ្តោះអាសន្ន៖ ដោយការចាត់ចែងប្រភេទនេះមាន២របៀបទៀត៖
  - ✓ ការចាត់ចែងបណ្តោះអាសន្នកម្មវត្ថុនៃវិវាទ៖ ការចាត់ចែងប្រភេទនេះ គឺជាការចាត់ចែងកម្មវត្ថុនៃការទាមទាររបស់ភាគីស្នើសុំ ដែលភាគីនោះបារម្ភថា បើកម្មវត្ថុនោះខូចខាត ឬប្រែប្រួលបច្ចុប្បន្នភាពរបស់វា នាំឱ្យភាគីស្នើសុំ ឬម្ចាស់បំណុលមិនអាច ឬលំបាកខ្លាំងក្នុងការអនុវត្តសិទ្ធិ
  - ✓ ការចាត់ចែងបណ្តោះអាសន្នលើការកំណត់ឋានៈជាបណ្តោះអាសន្ន៖ ការចាត់ចែងប្រភេទនេះ គឺជាការចាត់ចែងឋានៈរបស់បុគ្គលជាបណ្តោះអាសន្នសិន ដោយហេតុថា មានការបង្កគ្រោះថ្នាក់ ឬលំបាក និងទប់ស្កាត់បញ្ហាផ្សេងទៀត ដែលបណ្តាលមកពីភាពយឺតយ៉ាវ នៃការកំណត់ឋានៈរបស់បុគ្គលនោះ៕[64]

[63] ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦ មាត្រា៥៣១ (ប្រភេទនៃការចាត់ចែងរក្សាការពារ)។

[64] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកការរៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី *សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ* ទំព័រ ១៩៣។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើរួចមក ចាប់តាំងពីការចាប់ផ្តើមនៃការដាក់ពាក្យបណ្តឹង រហូតដល់ការបញ្ចប់បណ្តឹងនេះ យើងឃើញថា ដំណើរការរឿងក្តីនៅក្នុងសវនាការទាំងមូល ពិតជាមានភាពស្មុគស្មាញយ៉ាងខ្លាំង ជាពិសេស គឺទាក់ទងនឹងនីតិវិធីនៃការជំនុំជម្រះ និងការអនុវត្តសាលក្រមនេះតែម្តង។ ថ្វីត្បិតតែអត្ថបទនេះ ឬការដំណើរការរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូង មានលក្ខណៈស្មុគស្មាញបន្តិចមែន ប៉ុន្តែការពន្យល់ ក៏ដូចជាពាក្យពេចន៍ដែលបានប្រើប្រាស់នៅក្នុងអត្ថបទនេះ មិនមានភាពលំបាកក្នុងការស្វែងយល់ពេកទេ ពោលគឺ អត្ថបទទាំងមូលរៀបរៀង និងសរសេរឡើងដោយពាក្យ ប្រយោគ ឃ្លាឃ្លោងមានភាពសាមញ្ញៗតែប៉ុណ្ណោះ។ សរុបរួមមកវិញ យើងឃើញថានីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូង ដែលមានភាពត្រឹមត្រូវស្របតាមក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានសង្ខេបចេញជា៣ដំណាក់កាល។

ដំណាក់កាលទី១ គឺការចាប់ផ្តើមបណ្តឹងរដ្ឋប្បវេណី ឬការចាប់ផ្តើមដាក់ពាក្យបណ្តឹង ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដោយក្នុងបណ្តឹងនោះមានសរសេរពីកម្មវត្ថុនៃការទាមទារ និងមូលហេតុនៃការទាមទារ។ ដោយនៅត្រង់ដំណាក់កាលនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកតំណាងរបស់ខ្លួន ត្រូវធ្វើការត្រួតពិនិត្យពាក្យបណ្តឹង ឬភាគីក្នុងបណ្តឹងឱ្យបានច្បាស់លាស់ពីចំណុចដែលគួរសរសេរនៅក្នុងទម្រង់នៃពាក្យបណ្តឹង និងសមត្ថភាពរបស់ភាគីនៅក្នុងពាក្យបណ្តឹង។ ការសរសេរទម្រង់ពាក្យបណ្តឹង និងកំណត់សមត្ថភាពរបស់ភាគីក្នុងបណ្តឹងបានត្រឹមត្រូវ គឺជាកត្តាមួយចាំបាច់បំផុត ដើម្បីកុំឱ្យមានការយឺតយ៉ាវក្នុងដំណើរការបណ្តឹង ឬខាតពេលក្នុងការបង្គាប់ឱ្យកែតម្រូវដោយតុលាការ ឬក៏មានការច្រានចោលពាក្យបណ្តឹងនោះដោយតុលាការក៏ថាបាន ក្នុងករណីដែលភាគីបានដាក់ពាក្យបណ្តឹង ដែលមានលក្ខណៈផ្ទុយ ឬមិនស្របតាមការតម្រូវរបស់ច្បាប់ ឬមិនព្រមធ្វើការកែតម្រូវតាមការណែនាំរបស់តុលាការ។

ដំណាក់កាលទី២ គឺជាដំណើរការនៃការជម្រះក្តីលើកទី១ ឬហៅម្យ៉ាងទៀតបានថា ជាការជម្រះក្តីនៅសាលាដំបូង ដែលដំណាក់កាលនៃការជម្រះក្តីលើកទី១នេះ មាន២នីតិវិធីសំខាន់ៗទៀត គឺនីតិវិធីទី១ ជានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទី២ ជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលតុលាការស្តាប់សេចក្តីថ្លែងការណ៍របស់ភាគីខាងដើមចោទអំពីកម្មវត្ថុនៃការទាមទារ និងមូលហេតុនៃការទាមទារលើចំណុចវិវាទ និងស្តាប់ដូចគ្នាសេចក្តីថ្លែងការណ៍របស់ភាគីខាងចុងចម្លើយអំពីលទ្ធផលនៃការឆ្លើយតបនឹងការទាមទារក្នុងបណ្តឹងរបស់ដើមចោទ និងមូលហេតុនៃការច្រាលចោលការទាមទារនោះ។ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ជានីតិវិធីដែលតុលាការបើកសវនាកាជំនុំជម្រះរឿងក្តីដែលនីតិវិធីនេះ ភាគីនីមួយៗត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការពិនិត្យភស្តុតាងដោយតុលាការ ដើម្បីធ្វើការចេញសាលក្រមចុងក្រោយមួយ។

ដំណាក់កាលទី៣ ការបញ្ចប់បណ្ដឹង ដែលការបញ្ចប់បណ្ដឹងនេះ ជាដំណាក់កាលចុងក្រោយសម្រាប់ធ្វើការបិទបញ្ចប់បណ្ដឹងមួយ ដោយការបញ្ចប់បណ្ដឹងធ្វើទៅបានបន្ទាប់ពីការប្រកាសសាលក្រមចុងក្រោយរបស់តុលាការ។ ប៉ុន្តែស្ថិតក្នុងករណីខ្លះ បណ្ដឹងមិនបានបញ្ចប់ដោយសាលក្រមចុងក្រោយរបស់តុលាការរហូតទេ ដោយបណ្ដឹងខ្លះបញ្ចប់ដោយសកម្មភាពរបស់ភាគី ឬមរណភាពរបស់ភាគីជាដើម។ ការប្រកាសសាលក្រមចុងក្រោយរបស់តុលាការ គឺត្រូវធ្វើឡើងបន្ទាប់ពីការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងដោយតុលាការរួចរាល់ជាស្ថាពរ ដោយសាលក្រមចុងក្រោយនោះនឹងមានខ្លឹមសារសំខាន់មួយក្នុងចំណោមពីរ គឺសាលក្រមដែលមានខ្លឹមសារទទួលស្គាល់ការទាមរបស់ដើមចោទ និងសាលក្រមដែលមានខ្លឹមសារច្រានចោលការទាមរបស់ដើមចោទ។ ប៉ុន្តែនៅក្នុងករណីដែលតុលាការមិនអាចប្រកាសសាលក្រមចុងក្រោយបាន បន្ទាប់ពីបានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង នោះមានន័យថាការវិនិច្ឆ័យរបស់តុលាការ ដោយផ្អែកតាមលទ្ធផលនៃរឿងក្ដីនោះ ភាគីត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ម្ដងទៀត ទើបមានការវិនិច្ឆ័យ ឬសម្រេចសេចក្ដីជាថ្មីបាន។

ចំណុចសំខាន់មួយចំនួនទៀតដូចជានីតិវិធីនៃការដាស់តឿន នីតិវិធីនៃការអនុវត្តដោយបង្ខំ និងនីតិវិធីនៃការចាត់ចែងរក្សាការពារ ដែលជាផ្នែកនៃអត្ថបទនេះក៏មានសារៈសំខាន់ដែរ ព្រោះថានីតិវិធីទាំងនេះបង្កើតឡើងក្នុងគោលបំណងការពារសិទ្ធិរបស់បុគ្គល និងការពារផលប្រយោជន៍របស់បុគ្គលដែលជាម្ចាស់សិទ្ធិនោះដែរ។ នីតិវិធីនៃការដាស់តឿន មានគោលបំណងដាស់តឿនកូនបំណុល អំពីកាតព្វកិច្ចសងជាប្រាក់ទៅម្ចាស់បំណុល រីឯនីតិវិធីនៃការអនុវត្តដោយបង្ខំ មានគោលបំណងជួយម្ចាស់បំណុលក្នុងការអនុវត្តសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដោយបង្ខំឱ្យកូនបំណុលដែលបដិសេធមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះ ធ្វើការបំពេញកាតព្វកិច្ចរបស់ខ្លួនជាបន្ទាន់មុននឹងតុលាការចាត់វិធានការបន្ទាប់ និងនីតិវិធីនៃការចាត់ចែងរក្សាការពារ ក៏មានគោលបំណងជួយការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីម្ចាស់បំណុលដូចគ្នា ដោយធ្វើការរឹបអូសជាបណ្ដោះអាសន្ន ឬចាត់ចែងជាជាបណ្ដោះអាសន្នតាមការស្នើសុំរបស់ភាគីម្ចាស់បំណុល។

ទន្ទឹមនឹងនេះដែរ ក្រមនីតិវិធីរដ្ឋប្បវេណីបានរៀបរាប់ពីនីតិវិធីក្នុងការជម្រះក្ដីគ្រប់យ៉ាង ដែលក្រមនេះជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តជាក់ស្ដែង និងជាមូលដ្ឋានដ៏សំខាន់ដែរ ក្នុងការតាក់តែងអត្ថបទមួយនេះឡើង។ ដូច្នេះដើម្បីចូលរួមកាត់បន្ថយវិវាទខាងរដ្ឋប្បវេណី និងធ្វើការអភិវឌ្ឍច្បាប់រដ្ឋប្បវេណីឱ្យមានភាពប្រសើរឡើងជាងមុននោះ យើងទាំងអស់គ្នាដែលជានិស្សិតច្បាប់ ជាមន្ត្រីអនុវត្តច្បាប់ ជាស្ថាប័នតុលាការជម្រះក្ដី និងជាអ្នកសិក្សាស្វែងយល់វិស័យច្បាប់ទាំងអស់ សូមមេត្តាបន្តការយកចិត្តដាក់ និងចូលរួមបន្តទៀតក្នុងការសិក្សាស្វែងយល់ និងវិភាគច្បាប់រដ្ឋប្បវេណី ឬវិវាទរដ្ឋប្បវេណីដែលបានកើតមានឡើង ដើម្បីស្វែងរកដំណោះស្រាយថ្មីបន្ថែមដែលមានប្រសិទ្ធិភាពជាងមុន ៕

# អនុសាសន៍

# អនុសាសន៍

ដើម្បីធ្វើការឆ្លើយតបនឹងបញ្ហាចោទ ដែលកើតមាននៅជុំវិញ ដំណើរការនៃការជម្រះក្ដីលើកទី១ ឬការដំណើរការនៃនីតិវិធីរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង និងដើម្បីឱ្យមានភាពងាយស្រួលក្នុងការសិក្សាស្វែងយល់ឱ្យបានកាន់តែច្បាស់ ខ្ញុំបាទសូមធ្វើការឆ្លើយតបទៅកាន់ចំណោទបញ្ហាដោយមានលក្ខណៈចំៗ ដូចខាងក្រោមនេះ ៖

**១. ការឆ្លើយតបនឹងបញ្ហាលើការដាក់ពាក្យបណ្ដឹងក្នុងរឿងក្ដីរដ្ឋប្បវេណី**

_ ចំពោះការដាក់ពាក្យបណ្ដឹងឱ្យមានភាពត្រឹមត្រូវ សំខាន់គឺត្រូវផ្អែកលើចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង និងមូលហេតុនៃការធ្វើបណ្ដឹងនោះ ដោយការសរសេរពាក្យបណ្ដឹងនោះ រួមបញ្ចូលតែអង្គហេតុដែលជាភស្តុតាងសំខាន់ៗ និងជាប្រយោជន៍សម្រាប់តែក្នុងរឿងក្ដីប៉ុណ្ណោះ។ ការសរសេរពាក្យបណ្ដឹងបានត្រឹមត្រូវល្អ នាំឱ្យការដំណើរការអនុវត្តរបស់តុលាការមានភាពរលូន និងឆាប់រហ័ស ហើយក៏ទទួលបានផលល្អដល់អ្នកធ្វើបណ្ដឹងដែរ ដោយមិនបាច់ចំណាយពេលយូរ។

_ បើយល់ឃើញថាការដាក់ពាក្យបណ្ដឹង ឬសរសេរពាក្យបណ្ដឹងដោយខ្លួនឯង មានការលំបាកនោះ អ្នកគួររកបុគ្គលដែលសិក្សាផ្នែកច្បាប់ ដើម្បីជួយពិភាក្សា និងរំកញែកពីបញ្ហាលើការដាក់ពាក្យបណ្ដឹងនេះ ព្រោះថាអ្នកដែលមានចំណេះ និងជំនាញខាងវិស័យច្បាប់សុទ្ធសឹងតែអាចផ្ដល់យោបល់ល្អៗ និងមតិសំខាន់ៗ ដែលអាចជាប្រយោជន៍ក្នុងការធ្វើបណ្ដឹងរបស់យើងបាន។

_ មួយវិញទៀត អ្នកអាចសុំជំនួយពឹងពាក់ពីមេធាវីបាន ព្រោះថាមេធាវី គឺជាអ្នកតំណាងដោយអាណត្តិស្របច្បាប់ដែលតុលាការបានទទួលស្គាល់ ហើយការធ្វើបណ្ដឹងរឿងក្ដីវិវាទ ជាជំនាញ និងជាវិជ្ជាជីវៈរបស់ពួកគេទៅហើយ ដូច្នេះការពឹងពាក់មេធាវី ជាមធ្យោបាយមួយដែលនាំឱ្យការដំណើរការក្ដីប្រព្រឹត្តទៅដោយមានភាពឆាប់រហ័ស និងមានប្រសិទ្ធិភាពល្អ។

**២. ការឆ្លើយតបនឹងបញ្ហាសកម្មភាព ក្នុងពេលជម្រះក្ដីរដ្ឋប្បវេណី**

_ ចំណុចដែលគួរត្រៀមនៅមុនពេលបើកសវនាការជំនុំជម្រះក្ដី ដែលមានដូចជាភស្តុតាង សាក្សី និងចម្លើយផ្ទាល់មាត់ ដោយធ្វើយ៉ាងណាឱ្យការត្រៀមនោះ បានជាប្រយោជន៍ដល់ការជម្រះក្ដីរបស់យើង និងមានហេតុផលសមរម្យដើម្បីឱ្យតុលាការយល់ស្របតាម និងត្រូវត្រៀមឱ្យស្រេចដែរក្នុងនាមជាភាគី អ្វីដែលគួរនិយាយ និងអ្វីដែលមិនគួរនិយាយ ជៀសវាងនាំឱ្យអត្ថិភាពនៃការការពារផលប្រយោជន៍របស់យើងមានការធ្លាក់ចុះ ដោយសារការផ្ដល់ចម្លើយនោះ។

_ ចំណុចសំខាន់មួយទៀត គឺត្រូវមានវត្តមានគ្រប់កាលបរិច្ឆេទដែលតុលាការបានកោះហៅ ដើម្បីជៀសវាងលើការចោទប្រកាន់ផ្សេងៗ ព្រោះថាការដែលអវត្តមាននៅពេលកាលបរិច្ឆេទដែលតុលាការបានកោះហៅ អាចមាន

អត្ថន័យក្នុងការសន្និដ្ឋានបានដូចជាអំពើគេចវេស ការសារភាពដោយស្ម័គ្រចិត្ត ឬជាការទទួលស្គាល់ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីជាដើម។

**៣. ការឆ្លើយតបនឹងបញ្ហា ឬរបៀបនៃការអនុវត្តតាមសាលក្រមរបស់តុលាការ**

_ ដើម្បីឆ្លើយតបនឹងការប្រកាសសាលក្រមរបស់តុលាការ យើងត្រូវអនុវត្តតាមការណែនាំ ដែលមាននៅក្នុងអត្ថន័យនៃសាលក្រមនោះ ទោះបីជាយើងជាម្ចាស់បំណុល ឬកូនបំណុលក៏ដោយ ព្រោះថាវិសាលភាពនៃការអនុវត្តសាលក្រម គឺមានលើភាគីទាំងសងខាង ដោយមានភាគីម្ខាងអនុវត្តសិទ្ធិ និងភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ច ឬមានអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ច

_ ដើម្បីឆ្លើយតបនឹងការប្រកាសសាលក្រមរបស់តុលាការ ក្នុងវិធីសាស្ត្រផ្សេងទៀត គឺភាគីអាចធ្វើការបដិសេធមិនអនុវត្តតាមការសម្រេចដែលមានក្នុងសាលក្រមនោះបាន គឺដោយធ្វើការប្តឹងទៅតុលាការជាន់ខ្ពស់ អំពីការមិនសុខចិត្តលើសេចក្តីសម្រេចដែលតុលាការសាលាដំបូងបានប្រកាសនោះ៕

# ឯកសារយោង

# ឯកសារយោង

## ១.ឯកសារចម្បង

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមគ្មានលេខ ប្រកាសឱ្យប្រើ២៤ កញ្ញា ១៩៩៣។

ក្រមរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ប្រកាសឱ្យប្រើ០៨ ធ្នូ ២០០៧។

ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ប្រកាសឱ្យប្រើ០៦ កក្កដា ២០០៦។

ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើ០៦ សីហា ២០០៧។

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ប្រកាសឱ្យប្រើ២២ សីហា ១៩៩៥។

## ២. ឯកសារបន្ទាប់បន្សំ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកការរៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី *សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម*។

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកការរៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី *សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ*។

# ឧបសម្ព័ន្ធទី១
# ទម្រង់គំរូនៃពាក្យបណ្តឹង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

**ដើមចោទ:** ខ្ញុំបាទឈ្មោះ.........................................មានលំនៅដ្ឋានបច្ចុប្បន្ន...................................... តំណាងដោយលោក .....................តួនាទីជា ........................ ទូរស័ព្ទទំនាក់ទំនង .........................................។

**ចុងចោទ:** ឈ្មោះ .................. ភេទ............ថ្ងៃខែឆ្នាំកំណើត ............. កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ................ ចុះថ្ងៃទី ................ និង.................... ថ្ងៃខែឆ្នាំកំណើត .................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ............. ចុះថ្ងៃទី ......... មានទីលំនៅបច្ចុប្បន្ននៅភូមិ..........ឃុំ/សង្កាត់......... ស្រុក/ខណ្ឌ.................. ខេត្ត/ក្រុង .........................។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូង**................

**កម្មវត្ថុ:** ប្តឹងសុំឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម:

១. ......................................................
២. ......................................................

**យោង៖** - ......................................................
- ......................................................

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបអំពីដំណើររឿងដូចតទៅ៖ ................................ មានទីលំនៅបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់.......... ស្រុក/ខណ្ឌ......................... ខេត្ត/ក្រុង .............................................................................................................................................................................................................................................................................

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ ដូចមានក្នុងកម្មវត្ថុខាង លើដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅ..........................ថ្ងៃទី.............. ខែ............ ឆ្នាំ២០.......

ស្នាមមេដៃស្តាំ

**ឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុវត្តដោយបណ្តោះអាសន្ន

**ម្ចាស់បំណុលអនុវត្ត៖** ឈ្មោះ................ តំណាងស្របច្បាប់ដោយលោក .................... តួនាទី.............. អាសយដ្ឋាននៅ

ភូមិ........................................................................................................................................។

**កូនបំណុលអនុវត្ត៖** ឈ្មោះ .......... ភេទ................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .................. អាសយដ្ឋាននៅ

ភូមិ..............................................................................................................................................។

**សូមគោរពចូលមក**

**លោកប្រធានសាលាដំបូងខេត្ត/ក្រុង**....................

**កម្មវត្ថុ៖** សុំអនុវត្តបណ្តោះអាសន្ន ត្រង់សេចក្តីសម្រេចបញ្ចប់ ចំណុចទី .....នៃសាលក្រមរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ....... ខែ.........ឆ្នាំ២០................. របស់សាលាដំបូងខេត្ត/ក្រុង.......... លើអចលនវត្ថុដែលជា...................... មានផ្ទៃក្រឡា ............ ម៉ែត្រការ៉េ ជាដីលំនៅដ្ឋាន មានទីតាំងស្ថិតនៅភូមិ.................................................... ដើម្បីលក់ឡាយឡុងសងបំណុលមកឲ្យ.........................................................................។

**យោង៖** -សាលក្រមរដ្ឋប្បវេណីលេខ ......... ចុះថ្ងៃទី ....... ខែ........ ឆ្នាំ ២០....... របស់សាលាដំបូងខេត្ត/ក្រុង.............

-សម្រង់អនុវត្តសាលក្រមលេខ ............... ចុះថ្ងៃទី ........ ខែ ............... ឆ្នាំ២០..........

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ................. ចុះថ្ងៃទី................ ខែ............ ឆ្នាំ ២០......

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី ..... ខែ..... ឆ្នាំ ២០.... សាលាដំបូងខេត្ត/ក្រុង....... បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ លើសំណុំរឿងរដ្ឋប្បវេណីលេខ ..... ចុះថ្ងៃទី..... ខែ......... ឆ្នាំ២០...... ដោយបានសម្រេចសេចក្តី តាមសាលក្រមរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ..... ខែ ........ ឆ្នាំ២០..... របស់សាលាដំបូងខេត្ត/ក្រុង........ ត្រង់ចំណុចទី........ នៃនិច្ច័យសេចក្តីសម្រេចបញ្ចប់ ដែលមានខ្លឹមសារថា: សាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្នបានត្រង់និច្ច័យទី..... មានខ្លឹមសារថា: បង្គាប់ឲ្យចុងចម្លើយ ឈ្មោះ ....... សងប្រាក់ដើមចំនួន ............... ឲ្យមកដើមចោទ ................................ ។

ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលអនុវត្ត ស្របតាមខ្លឹមសារ នៃ សាលក្រមរដ្ឋប្បវេណីលេខ .......... ចុះថ្ងៃទី ...... ខែ .............. ឆ្នាំ២០.............របស់សាលាដំបូងខេត្ត/ក្រុង....... ខ្ញុំបាទស្នើសុំអនុវត្តជាបណ្តោះអាសន្ននូវចំណុចខាងលើ ដោយអនុវត្តដោយបង្ខំលើអចនវត្ថុដូចបានបញ្ជាក់ក្នុងកម្មវត្ថុខាងលើ ដើម្បីលក់ឡាយឡុងសងបំណុលមកម្ចាស់បំណុលអនុវត្ត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ ដូចបានបញ្ជាក់ក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ធ្វើនៅ.......... ថ្ងៃទី.....ខែ............ ឆ្នាំ២០....

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំឲ្យផ្ដល់រូបមន្តអនុវត្ត

**សូមគោរពជូន**

**លោក ....................... ចៅក្រមសាលាដំបូង..................**

ម្ចាស់បំណុលនៃការអនុវត្ត: ឈ្មោះ................ តំណាងស្របច្បាប់ដោយលោក ......... តួនាទីជា........................ មានអាសយដ្ឋាន ភូមិ.............................................................................។

កូនបំណុលនៃការអនុវត្ត: ឈ្មោះ .......... ភេទ......... អាយុ.......................ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅ ភូមិ .................................................................................................................................។

សញ្ញាណនៃលិខិតអនុវត្ត: សាលក្រមរដ្ឋប្បវេណីលេខ: ....... ចុះថ្ងៃទី..... ខែ..... ឆ្នាំ២០........... របស់សាលាដំបូង ខេត្ត/ក្រុង........................។

ហេតុការណ៍ និងមូលហេតុនៃការសុំឲ្យផ្ដល់រូបមន្តនៃការអនុវត្តន៍បណ្ដោះអាសន្ន ដោយហេតុថា: យោងសេចក្ដីសម្រេចបញ្ចប់ក្នុងសាលក្រមលេខ ......... ចុះថ្ងៃទី...... ខែ........ ឆ្នាំ២០...... របស់សាលាដំបូងខេត្ត/ក្រុង.......... ត្រង់ចំណុចទី ........ នៃសេចក្ដីសម្រេចបានចែងថា: សាលក្រមនេះមានអានុភាពអនុវត្តជាបណ្ដោះអាសន្ន ត្រង់ចំណុចទី ..............នៃសេចក្ដីសម្រេចបញ្ចប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកចៅក្រម** មេត្តាពិនិត្យ និងសម្រេចតាមនីតិវិធីដោយក្ដីអនុគ្រោះ។
សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ធ្វើនៅ.................. ថ្ងៃទី....... ខែ....... ឆ្នាំ២០.....

ស្នាមមេដៃស្ដាំ

**ឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## **<u>កិច្ចព្រមព្រៀងលែងលះ</u>**

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី ....... ខែ ...... ឆ្នាំ..........រវាង៖

ឈ្មោះ ................. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត:........................ មានទីលំនៅផ្ទះលេខ: ........... ផ្លូវ................ សង្កាត់ ................ ខណ្ឌ ................ រាជធានីភ្នំពេញ ភាគីប្ដីតទៅនេះហៅគាត់ថា **ភាគី-ក-**។

**<u>និង</u>**

ឈ្មោះ .................. ភេទ ស្រី ថ្ងៃខែឆ្នាំកំណើត: .................... មានទីលំនៅផ្ទះលេខ: .............. ផ្លូវ ................ សង្កាត់.................. ខណ្ឌ ................ រាជធានីភ្នំពេញ ។

**<u>មូលហេតុ</u>**

**ដោយហេតុថា**: **ភាគី -ក-** និង **ភាគី -ខ-** បានរៀបការជាមួយគ្នានៅឆ្នាំ ............ និងបានចុះសំបុត្ររាពាហ៍ពិពាហ៍នៅថ្ងៃទី.......... ខែ .......... ឆ្នាំ .......... នៅសាលាខណ្ឌ ............ រាជធានីភ្នំពេញ ហើយបង្កើតបានកូនចំនួន ........... នាក់ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ២១.០១.២០០១។ ការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធនេះតែងតែមានភាពរកាំរកូស ពុំមានសេចក្ដីសុខក្នុងគ្រួសារ មិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន ហើយយើងខ្ញុំក៏អស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្ដីប្រពន្ធជាមួយគ្នា និង ព្រមព្រៀងលែងលះឈប់រស់នៅជាមួយគ្នាជាប្ដីប្រពន្ធចាប់ពីពេលនេះតទៅ ។

**<u>ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមកភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោយ</u>**:

**<u>ប្រការ១</u>**: **ភាគី -ក-** និង **ភាគី -ខ-** ឯកភាពយល់ព្រមលែងលះឈប់រស់នៅជាមួយគ្នាជាប្ដីប្រពន្ធដោយស្ម័គ្រចិត្តពីថ្ងៃចុះហត្ថលេខា និងផ្ដិតមេដៃនេះតទៅ ។

ទ្រព្យសម្បត្តិរួមមាន៖

មានកូនឈ្មោះ .............. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ...................................................។

